បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2013

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

២៥-៧-២០០១ - ព្រះរាជក្រម នស/រកម/០៧០១/១០ ស្ដីពីការយល់ព្រមនិងការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការ ប្រតិបត្តិ សំរេចមជ្ឈត្តករ បរទេស ១៩០៦

២៨-៧-២០០១ - ព្រះរាជក្រម នស/រកម/០៧០១/១១ ស្ដីពីការប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ ធម្មនុញ្ញស្ដីពីវិសោធនកម្ម មាត្រា ១៩ និងមាត្រា២៨ នៃរដ្ឋ ធម្មនុញ្ញនៃព្រះ រាជាណាចក្រកម្ពុជា ១៩១៨

### ២-ព្រះរាជក្រឹត្យ

២៣-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀន កំរិតឧត្ដម ១៩១៩

២៣-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ១៩២៩

២៥-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤២ ស្ដីពីការបង្កើតរូបសញ្ញារដ្ឋបាល សញ្ញាសក្តិនិងឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងក្របខ័ណ្ឌក្រមការ ដែលបំរើការងារតាមក្រសួង-ស្ថាប័ន នានានៃព្រះរាជាណាចក្រកម្ពុជា ១៩៣៨

២៦-៧-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៤ ស្ដីពីការតែងតាំងឯកឧត្ដម **ខៀវ សាម៉េត** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ១៩៥៥

២៦-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៥ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក (Jeau Pierre MARTIAL) សញ្ជាតិ ជើមបារាំង ១៩៥៦

២៦-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៦ ស្ដីពីការបំពាក់មេដាយ ព្រះរាជា ណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ជូនឯកឧត្ដម **លឹម កានហោ** រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយម ១៩៥៧

២៦-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៧ ស្ដីពីការតែងតាំងឯកឧត្ដម **ខែក ឡឺរ៉ង់** ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន ១៩៥៨

២៨-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៨ តែងតាំងឯកឧត្ដម **អ៊ុច ហួត** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** ១៩៥៩

២៨-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៤៩ តែងតាំងលោកជំទាវ គេត ថុល ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ១៩៦០

៣០-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៥០ តែងតាំងឯកឧត្តម ញាណ ឡេង ជាអនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជំនួសឯកឧត្តម អ៊ុត ឈន ដែលផ្លាស់ទៅទទួល ភារកិច្ចថ្មី ១៩៦១

៣១-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៥១ តែងតាំងឯកឧត្តម ចំនួ តុងអ៊ីវ រដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជា ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈ ស្មើ រដ្ឋមន្ត្រី ១៩៦២

៣១-៧-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៥២ តែងតាំងឯកឧត្តម ស៊ិន ពិនសេន (ហៅ ស៊ិន សេន ) ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម ស៊ិន ម៉ូ ដែលបានលាឈប់ ទៅបំពេញភារកិច្ចថ្មី ១៩៦៣


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៥-៧-២០០១ - អនុក្រឹត្យ លេខ ៦៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៩៦៤

២៥-៧-២០០១ - អនុក្រឹត្យ លេខ ៦៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៩៦៦

២៧-៧-២០០១ - អនុក្រឹត្យ លេខ ៧០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១៩៦៨

៣១-៧-២០០១ - អនុក្រឹត្យ លេខ ៧១ អនក្រ.បក ស្តីពីបទដ្ឋាន និងនីតិវិធីគ្រប់គ្រង ចំណូល-ចំណាយសំរាប់ដំណើរការងារបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា ឃុំ-សង្កាត់ ១៩៨៣

៣១-៧-២០០១ - អនុក្រឹត្យ លេខ ៧២ អនក្រ.បក ស្តីពីដាក់ឱ្យមន្ត្រីរាជការ ឱ្យនៅក្រៅ ក្របខ័ណ្ឌដើមក្នុងពេលបំពេញការងាររៀបចំការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា ឃុំ-សង្កាត់ ១៩៨៨

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៩១

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៩៣

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៦ អនក្រ.តត ស្តីពីការតែងតាំងលោក អោក ទ៉េត ជាអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ១៩៩៤

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៧ អនក្រ.តត ស្តីពីការតែងតាំងលោក ហើស សារីធន ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណ រដ្ឋឥណ្ឌា ១៩៩៥

# គ

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៨ អនក្រ.តរ ស្តីពីការផ្លាស់ប្តូរលោក **ហែម ហេង** បច្ចុប្បន្ន ជាអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេស ឥណ្ឌា ឱ្យមកបំរើការងារនៅក្នុងប្រទេសវិញ ១៩៩៦

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣១៩ អនក្រ.តត ស្តីពីការបំពាក់មេដាយសុវត្ថារា ថ្នាក់ " ធិបឌិន្ទ " ជូនលោកជំទាវ **ផ្លេក តិរុណា** ១៩៩៧

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣២០ អនក្រ.តត ស្តីពីការបំពាក់មេដាយសុវត្ថារា ថ្នាក់ " ធិបឌិន្ទ " ជូនឯកឧត្តមអ្នកឧកញ៉ាវិសេសវិជ្ជា **ម៉ សាមីឌី** ១៩៩៨

២៤-៧-២០០១ - អនុក្រឹត្យ លេខ ៣២១ អនក្រ.តត ស្តីពីការបំពាក់មេដាយសុវត្ថារា ថ្នាក់ " **សេនា** " ជូនលោក :

១-លោក MASAO MIYAZAKA ជំនាញការ JICA អមក្រសួងធនធានទឹកនិង ឧតុនិយម

២-លោក Histoshi TOKU តំណាងក្រុមហ៊ុន SANYO Consultant Inc ប្រចាំគំរោងព្រែកនាំដីល្បប់ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ១៩៩៩

២៧-៧-២០០១ - អនុក្រឹត្យ លេខ ៣២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ១០នាក់ ២០០០

២៧-៧-២០០១ - អនុក្រឹត្យ លេខ ៣២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២០០២

២៧-៧-២០០១ - អនុក្រឹត្យ លេខ ៣២៤ អនក្រ.តត ស្តីពីការបំពាក់មេដាយស្ថាបនាជាតិ ជូនលោក វ៉ិត ជូ ២០០៤

២៧-៧-២០០១ - អនុក្រឹត្យ លេខ ៣២៥ អនក្រ.តត ស្តីពីការបំពាក់មេដាយស្ថាបនាជាតិ ដល់សប្បុរសជន ចំនួន ២៨រូប ២០០៥

៣១-៧-២០០១ - អនុក្រឹត្យ លេខ ៣២៦ អនក្រ.តត ស្តីពីការបំពាក់មេដាយស្ថាបនាជាតិ ២០០៧

៣១-៧-២០០១ - អនុក្រឹត្យ លេខ ៣២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០០៨

៣១-៧-២០០១ - អនុក្រឹត្យ លេខ ៣២៨ អនក្រ.តត ស្តីពីការតែងតាំងលោក **អ៊ិន សារឿន** ជាចារីបេសកកម្ម អមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៩

## ២.សេចក្តីសំរេច

៣១-៧-២០០១ - សេចក្តីសំរេច លេខ ៤២ សសរ ស្តីពីការបង្កើតក្រុមការងារចុះត្រួត ពិនិត្យ បាតុភាពនៅប្រាសាទព្រះវិហារ ២០១០

## ៣.សារាចរណែនាំ

២៤-៧-២០០១ - សារាចរណែនាំ លេខ ១០ សរណន ស្តីពីការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា ២០១៥

# ឃ

## III- ការងារបណ្ណាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

#### ប្រកាស

| | | |
|---|---|---|
| ២៧-៧-២០០១ | -ប្រកាសលេខ ៥១៥ សហវ ស្តីពីការប្រើប្រាស់តែមប្រឹអាករ សំរាប់បញ្ជាក់ ការបង់ប្រាក់អាករពិសេសលើទំនិញ និងសេវាមួយចំនួន សំរាប់បារី | ២០១៩ |

### ២_ទីស្តីការរដ្ឋមន្ត្រី ក្រសួង ពាណិជ្ជកម្ម

#### ប្រកាស

| | | |
|---|---|---|
| ៣០-៧-២០០១ | -ប្រកាសលេខ ២០៥ MOC/M2001 ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ដែលត្រូវបាននាំចេញទៅសហរដ្ឋអាមេរិក សំរាប់ឆ្នាំ ២០០១ | ២០២៥ |

# ព្រះរាជក្រម

នស/រកម/០៧០១/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជរិទព្យ ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៕

# ច្បាប់

# ស្តីពី

# ការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ

# ស្តីពីការទទួលស្គាល់និងការប្រតិបត្តិ

# សេចក្តីសម្រេចមជ្ឈត្តការបរទេស

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះចែងអំពីការយល់ព្រមនិងការអនុវត្តនូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបានធ្វើនៅទីក្រុងញូវយ៉ក ថ្ងៃ ១០ ខែ មិថុនា ឆ្នាំ ១៩៥៨ និងដែលបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៦០ ។ ច្បាប់នេះក៏កំណត់អំពីនីតិវិធីនិងសមត្ថកិច្ចនៃតុលាការព្រះរាជាណាចក្រកម្ពុជាដែរ នៅពេលមានការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ដោយផ្អែកលើអនុសញ្ញាទីក្រុងញូវយ៉ក ដូចមានចែងខាងលើ ។

## ជំពូកទី ២
## និយមន័យ

**មាត្រា ២.-**

សម្រាប់ការអនុវត្តនូវច្បាប់នេះ ពាក្យថា :

១-សេចក្តីសម្រេចមជ្ឈត្តករបរទេសមានន័យថា សេចក្តីសម្រេចរបស់អង្គអាជ្ញាកណ្តាលមួយ ដែលបានធ្វើនៅក្នុងប្រទេសណាមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា ឬ នៅក្រោមនីតិវិធីនៃច្បាប់របស់ប្រទេសមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា ។

២-មជ្ឈត្តវិនិច្ឆ័យមានន័យថា សេចក្តីសម្រេចនៃអាជ្ញាកណ្តាលណាមួយទោះមានការគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តករអចិន្ត្រៃយ៍ក្តី ឬ មិនមែនអចិន្ត្រៃយ៍ក្តី ។

៣-អនុសញ្ញាទីក្រុងញូវយ៉កមានន័យថាអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបានធ្វើនៅទីក្រុងញូវយ៉ក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៥៨ ។

៤-សាលាឧទ្ធរណ៍មានន័យថា អង្គវិនិច្ឆ័យនៃសាលាឧទ្ធរណ៍ក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពចៅក្រមពេញសិទ្ធិ ៣ (បី) រូប ។

៥-តុលាការកំពូលមានន័យថា អង្គវិនិច្ឆ័យនៃតុលាការកំពូលព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពចៅក្រមពេញសិទ្ធិ ៥ (ប្រាំ) រូប ។

៦-តុលាការកម្ពុជាមានន័យថា សាលាឧទ្ធរណ៍ឬតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចដើម្បីពិនិត្យឡើងវិញ និងវិនិច្ឆ័យអំពីការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

៧-ផ្ទុយនឹងបន្ទាត់នយោបាយសាធារណៈមានន័យថា សេចក្តីសម្រេចដែលនាំឱ្យផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។

## ជំពូកទី ៣
## សមត្ថកិច្ចនិងដែនអនុវត្ត

**មាត្រា ៣.-**

តុលាការកម្ពុជាត្រូវបានប្រគល់សមត្ថកិច្ចវិនិច្ឆ័យលើសំណើសុំការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ។

**មាត្រា ៤.-**

តុលាការកម្ពុជាត្រូវតែសម្រេចឱ្យស្របតាមអនុសញ្ញាទីក្រុងញូវយ៉ក ក្នុងការវិនិច្ឆ័យលើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

**មាត្រា ៥.-**

តុលាការកម្ពុជាត្រូវទទួលពាក្យស្នើសុំពីអ្នកដាក់ពាក្យសុំឱ្យមានការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ទោះអ្នកសុំមានសញ្ជាតិអ្វីក៏ដោយ ។

**មាត្រា ៦.-**

អ្នកសុំការទទួលស្គាល់និងការប្រតិបត្តិត្រូវចាប់ផ្តើមដាក់ពាក្យសុំជាដំបូងទៅសាលាឧទ្ធរណ៍ ។ល។

## ជំពូកទី ៤
## នីតិវិធី

**មាត្រា ៧.-**

ដើម្បីទទួលបាននូវការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសណាមួយ ភាគីដែលដាក់ពាក្យសុំការទទួលស្គាល់និងការប្រតិបត្តិត្រូវផ្ដល់សំណៅដើមត្រឹមត្រូវតាមច្បាប់នៃសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេស ឬក៏សំណៅថតចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ ហើយនិងច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តវិនិច្ឆ័យដែលភាគីទាំងពីរបានធ្វើ ឬក៏សំណៅថតចម្លងនៃកិច្ចសន្យាដែលមានការបញ្ជាក់ត្រឹមត្រូវ ។ បើសិនជាសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសឬកិច្ចសន្យាពុំមែនជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាទេ ភាគីត្រូវតែផ្ដល់ការបកប្រែដែលមានការបញ្ជាក់ត្រឹមត្រូវ ។

**មាត្រា ៨.-**

សាលាឧទ្ធរណ៍ ក្រោយពីថ្ងៃទទួលពាក្យសុំឱ្យមានការទទួលស្គាល់និងការប្រតិបត្តិ ត្រូវធ្វើលិខិតជូនដំណឹងអំពីបណ្ដឹងនេះទៅភាគីដែលសេចក្ដីសម្រេចត្រូវអនុវត្តចំពោះខ្លួន ក្នុងរយៈពេល ១០ (ដប់) ថ្ងៃប្រតិទិន ក្រោយពីតុលាការបានទទួលនូវពាក្យស្នើសុំ ។

**មាត្រា ៩.-**

ភាគីដែលសេចក្ដីសម្រេចត្រូវអនុវត្តចំពោះខ្លួន មានសិទ្ធិប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍កុំឱ្យទទួលស្គាល់និងកុំឱ្យប្រតិបត្តិនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេស ដោយផ្ដល់នូវភស្តុតាងយ៉ាងរឹងមាំនិងនូវមូលដ្ឋានណាមួយស្របច្បាប់ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន ក្រោយពីសាលាឧទ្ធរណ៍បានទទួលនូវពាក្យសុំឱ្យទទួលស្គាល់និងការប្រតិបត្តិ។

**មាត្រា ១០.-**

ក្នុងករណីការប្ដឹងទាស់បានធ្វើទាន់ពេលវេលា សាលាឧទ្ធរណ៍ត្រូវចេញសេចក្ដីសម្រេចបញ្ជាក់លើសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសថា ត្រូវបានទទួលស្គាល់ឬមិនត្រូវបានទទួលស្គាល់ និងមិនត្រូវប្រតិបត្តិក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃប្រតិទិនចាប់ត.

ពីថ្ងៃដែលបានទទួលពាក្យសុំកុំឱ្យទទួលស្គាល់និងកុំឱ្យប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

**មាត្រា ១១.-**

សាលាឧទ្ធរណ៍អាចតម្រូវឱ្យអ្នកដាក់ពាក្យជំទាស់ដាក់ប្រាក់ធានា ក្នុងទឹកប្រាក់ដែលមិនឱ្យលើសពីចំនួនទឹកប្រាក់នៃសេចក្តីសម្រេចមជ្ឈត្តករបរទេស បូកនឹងការប៉ាន់ស្មានកម្រៃសេវាមេធាវីនិងសោហ៊ុយផ្សេងទៀតលើការវិនិច្ឆ័យ ។ ប្រសិនបើអ្នកដាក់ពាក្យសុំជំទាស់មិនមានលទ្ធភាពដាក់ប្រាក់ធានាដូចបានចែងខាងលើទេ សាលាឧទ្ធរណ៍ត្រូវចេញបញ្ជាឃាត់ទុកជាបណ្តោះអាសន្នឬបើពុំនោះទេ ។ កាន់កាប់ជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិឬទ្រព្យធនដទៃទៀតដែលជាកម្មសិទ្ធិរបស់អ្នកប្តឹងទាស់ ។

**មាត្រា ១២.-**

សាលដីកាសាលាឧទ្ធរណ៍ឬសាលដីកាតុលាការកំពូលដែលទទួលស្គាល់និងប្រតិបត្តិ ឬបដិសេធមិនទទួលស្គាល់និងមិនប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសត្រូវចាត់ទុកថាជាសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ហើយត្រូវអនុវត្តឱ្យស្របតាមនីតិវិធីជាធរមានស្តីពីការអនុវត្តសាលដីកា ។

**មាត្រា ១៣.-**

ក្នុងពេលរង់ចាំសេចក្តីសម្រេចចុងក្រោយពីតុលាការកម្ពុជា ភាគីណាមួយដែលពាក់ព័ន្ធលើសេចក្តីសម្រេចនៃមជ្ឈត្តករបរទេស នៅពេលណាក៏បានអាចដាក់ពាក្យតវ៉ាទៅសាលាឧទ្ធរណ៍ចាត់វិធានការបណ្តោះអាសន្ននិងដើម្បីការពារដល់សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យរួមមានការចេញសេចក្តីសម្រេចឃាត់ឃាំងឬស្នើសុំសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិកូនបំណុលជាបណ្តោះអាសន្ន ឬទ្រព្យសម្បត្តិដទៃទៀតដែលជាកម្មសិទ្ធិនៃភាគីម្ខាងទៀត ឬភាគីច្រើនដែលពាក់ព័ន្ធនឹងមជ្ឈត្តវិនិច្ឆ័យ ។ល។

## ជំពូកទី ៥
## មូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់ឬ/និងការប្រតិបត្តិ

**មាត្រា ១៤.-**

តុលាការកម្ពុជាអាចធ្វើការបដិសេធនូវការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេស ដោយយោងលើចំណុចទាំងឡាយនៃមាត្រា ១៥ និង ១៦ ខាងក្រោម ។

**មាត្រា ១៥.-**

ការបដិសេធលើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេស នឹងអាចធ្វើទៅបានលុះត្រាតែ ៖

ក-តាមសំណើរបស់ភាគីដែលខ្លួនត្រូវគេអំពាវនាវរកពាក់ព័ន្ធនឹងបណ្ដឹងឱ្យមានការទទួលស្គាល់និងប្រតិបត្តិ ប្រសិនបើភាគីរូបនេះបង្ហាញភស្តុតាងទៅតុលាការថា ៖

១-ភាគីដែលបានចុះកិច្ចព្រមព្រៀងមជ្ឈត្តការដែលបានដាក់ពាក្យទៅតុលាការមានសមត្ថកិច្ច ស្ថិតក្នុងករណីអសមត្ថភាព ឬកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខានេះក្រោមច្បាប់មួយ ដែលភាគីសងខាងត្រូវតែគោរពតាម គ្មានសុពលភាព ឬកិច្ចព្រមព្រៀងមិនបានបង្ហាញនូវចំណុចណាមួយច្បាស់លាស់ក្រោមច្បាប់នៃប្រទេសណាមួយ ដែលការសម្រេចមជ្ឈត្តករបរទេសបានធ្វើឡើង ឬ

២-ភាគីដែលសេចក្ដីសម្រេចមជ្ឈត្តករបរទេសត្រូវអនុវត្តចំពោះខ្លួន ពុំបានទទួលនូវសេចក្ដីជូនដំណឹងត្រឹមត្រូវស្ដីពីការតែងតាំងមជ្ឈត្តករ ឬ ពីនីតិវិធីនៃអាជ្ញាកណ្ដាល ឬ បើពុំនោះទេ ខ្លួនពុំអាចចូលតវ៉ាពីក្ដី របស់ខ្លួនបានឡើយ ឬ

៣-សេចក្ដីសម្រេចនៃមជ្ឈត្តករបរទេសស្ដីពីជម្លោះដែលមិនស្រប ឬ មិនចូលក្នុងន័យនៃការដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យ ឬសេចក្ដីសម្រេចដែលមានខ្លឹមសារហួសពីវិសាលភាពនៃការដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យ ។ តែប្រសិនបើសេចក្ដីសម្រេចដែលបានដាក់សុំមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានបំបែកចេញពីរឿងដែលពុំបានដាក់ស្នើចំណែកនៃសេចក្ដីសម្រេចមជ្ឈត្តករបរទេសដែលមានសេចក្ដីសម្រេចលើរឿងដែលបានដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានទទួលស្គាល់និងប្រតិបត្តិ ឬ ល។

៤-សមាសភាពនៃសាលាធ្វើមជ្ឈត្តវិនិច្ឆ័យឬនីតិវិធីនៃមជ្ឈត្តវិនិច្ឆ័យ មានលក្ខណៈពុំស្របនឹងកិច្ចសន្យារបស់ភាគីឬក្នុងករណីដែលគ្មានកិច្ចសន្យាបែបនេះ សមាសភាពដែលធ្វើមជ្ឈត្តវិនិច្ឆ័យពុំស្របតាមច្បាប់នៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យបានធ្វើ ឬ

៥-សេចក្តីសម្រេចនៃមជ្ឈត្តករបរទេសពុំទាន់មានភ្ជាប់កាតព្វកិច្ចលើភាគីទាំងឡាយឬត្រូវបានទុកមួយអន្លើសិនឬផ្អាកដោយតុលាការឬដោយច្បាប់នៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យនោះបានសម្រេចឡើងឬ

ខ-តុលាការកម្ពុជារកឃើញថា :

១-រឿងក្តីដែលមានទំនាស់នេះ មិនអាចនឹងធ្វើការដោះស្រាយតាមវិធីមជ្ឈត្តកម្មបានក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

២-ការទទួលស្គាល់ឬការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសផ្ទុយនឹងបន្ទាត់នយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងការកំណត់ស្តង់-ដារ នៃបន្ទាត់នយោបាយសាធារណៈដែលត្រូវអនុវត្តដើម្បីបដិសេធការវិនិច្ឆ័យរបស់មជ្ឈត្ត-ករបរទេសតុលាការត្រូវពិចារណាលើស្តង់ដារនៃបន្ទាត់នយោបាយសាធារណៈដែលបានអនុវត្តដោយតុលាការនៃរដ្ឋដទៃទៀតដែលជាភាគីនៃអនុសញ្ញាទីក្រុងញូវយ៉ក ។

**មាត្រា ១៦.-**

យោងតាមកថាខណ្ឌ (ក) (៥) នៃមាត្រា ១៥ ក្នុងករណីដែលមានពាក្យបណ្តឹងសុំបដិសេធការទទួលស្គាល់នឹងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករ ប្រសិនបើតុលាការកម្ពុជាដែលទទួលនូវពាក្យសុំពិចារណាទៅឃើញថាសមស្រប តុលាការកម្ពុជាអាចពន្យារសេចក្តីសម្រេចរបស់ខ្លួនហើយក៏អាចបញ្ជាឱ្យភាគីម្ខាងទៀតបង់នូវប្រាក់ធានាដ៏សមស្រប ។ល។

## ជំពូកទី ៦
## សិទ្ធិអំណាចនិងសមាសភាពសាលាឧទ្ធរណ៍

**មាត្រា ១៧.-**

សាលាឧទ្ធរណ៍ ក្រោយពីបានទទួលពាក្យបណ្តឹងអស់រយៈពេលហុកសិប (៦០)ថ្ងៃ ប្រតិទិននៅចុងម៉ោងធ្វើការ ក្នុងករណីដែលគ្មានពាក្យស្នើសុំដើម្បីបដិសេធការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តការបរទេសត្រូវធ្វើការសម្រេចទទួលស្គាល់ សេចក្តីសម្រេចមជ្ឈត្តការបរទេសនោះ ។ សាលាឧទ្ធរណ៍ត្រូវធ្វើការចុះបញ្ជីនៅក្នុងបញ្ជី សៀវភៅសេចក្តីសម្រេចនៃសាលាឧទ្ធរណ៍ ហើយត្រូវចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ នូវសេចក្តីសម្រេចមជ្ឈត្តការបរទេសជាសេចក្តីសម្រេចចុងក្រោយនិងជាស្ថាពរ និងត្រូវ អនុវត្តសេចក្តីសម្រេចនេះភ្លាមៗតាមច្បាប់និងនីតិវិធីដែលមានជាធរមាន ។ ក្នុងករណី បែបនេះសាលដីកាសាលាឧទ្ធរណ៍ គឺជាសេចក្តីសម្រេចចុងក្រោយ និងជាស្ថាពរមិនអាច ជាកម្មវត្ថុប្តឹងជំទាស់នៅតុលាការកំពូលទៀតទេ ។

**មាត្រា ១៨.-**

សាលាឧទ្ធរណ៍ត្រូវពិចារណានូវសេចក្តីសម្រេចរបស់ខ្លួនឱ្យបានហ្មត់ចត់ស្របតាម ល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះ មុននឹងសម្រេចបដិសេធ ការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តការបរទេស ។

**មាត្រា ១៩.-**

សាលាឧទ្ធរណ៍ នៅពេលធ្វើការសម្រេចការទទួលស្គាល់និងការប្រតិបត្តិឬបដិសេធ ការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តការបរទេសលើកលែងតែមាត្រា ១៧ ខាងលើ ត្រូវបើកផ្លូវឱ្យភាគីម្ខាងទៀតធ្វើការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ខ្លួនទៅ តុលាការកំពូលក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ ប្រតិទិនគិតពីថ្ងៃចេញសេចក្តីសម្រេច ។

**មាត្រា ២០.-**

សាលាឧទ្ធរណ៍ ក្នុងសវនាការដើម្បីសំរេចលើករណីចំពោះមុខដូចខាងលើនេះត្រូវ មានសមាសភាពចៅក្រមពេញសិទ្ធិចំនួន ៣(បី) រូប ។៚

# ជំពូកទី ៧

## សិទ្ធិ អំណាចនិងសមាសភាពតុលាការកំពូល

**មាត្រា ២១.-**

តុលាការកំពូលជាសាលាជំរះក្តីដែលមានសមត្ថកិច្ចជំនុំជំរះបណ្តឹងជំទាស់របស់ភាគីម្ខាងទៀតដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលទទួលស្គាល់និងប្រតិបត្តិឬបដិសេធការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ។

**មាត្រា ២២.-**

តុលាការកំពូលត្រូវជំនុំជំរះចេញសាលដីកា ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលភាគីបានដាក់ពាក្យបណ្តឹង ដោយពុំចាំបាច់បញ្ជូនសំណុំរឿងត្រឡប់មកសាលាឧទ្ធរណ៍ឱ្យពិនិត្យសម្រេចឡើងវិញទេ ។

**មាត្រា ២៣.-**

សាលដីកាតុលាការកំពូលជាសេចក្តីសម្រេចចុងក្រោយនិងស្ថាពរហើយមិនត្រូវជាកម្មវត្ថុប្តឹងជំទាស់ឬប្តឹងតវ៉ាផ្សេងៗទៀត ដោយមធ្យោបាយណាមួយឡើយ ។

**មាត្រា ២៤.-**

តុលាការកំពូលត្រូវចាត់វិធានការធ្វើការអនុវត្តភ្លាមៗនូវសាលដីការបស់ខ្លួនអំពីសេចក្តីសម្រេចដែលបានធ្វើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ២៥.-**

តុលាការកំពូល ក្នុងសវនាការដើម្បីសម្រេចលើករណីដូចខាងលើនេះ ត្រូវមានសមាសភាពចៅក្រមពេញសិទ្ធិចំនួន ៥(ប្រាំ) រូប ។ល។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

# ជំពូកទី ៨

# អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះមានប្រសិទ្ធិភាពអនុវត្តតែក្នុងករណីមជ្ឈត្តករ បរទេសប៉ុណ្ណោះ ។

**មាត្រា ២៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១

បានបង្កិតថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

ព្រះរាជហស្តលេខា

នរោត្តម សីហនុ

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខ: ១៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់ធម្មនុញ្ញ
## ស្តីពី
## វិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ** : មាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

**មាត្រា ២៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិលតាមច្បាប់កំណត់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ។

ភ្នំពេញ,ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០១

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ

# ព្រះរាជក្រម

នស/រកម/០៧០១/១១

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានទ្រង់យល់លទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ នៅថ្ងៃច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់លទ្ធផលសម័យប្រជុំព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ១ នៅថ្ងៃច័ន្ទទី ២៣ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់លិខិតស្នើសុំរបស់សម្តេចព្រះប្រធានរដ្ឋសភា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

មាត្រា ១ : ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ ២០០១ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃច័ន្ទ ទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ៕

មាត្រា ២ : ព្រះរាជក្រមនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ៕

នរោត្តម សីហនុ

ធ្វើនៅភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៤០

## ស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌគ្រូបង្រៀនកីឡាឧត្តម

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូល ស្នើសុំ ពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១ ស.រ.

## ត្រាស់បង្គាប់

## ជំពូក ទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌ គ្រូបង្រៀនកិរិតឧត្តមដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យ លេខ ជស-រកត ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌ គ្រូបង្រៀនកិរិតឧត្តមស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា ប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេស ខាងគរុកោសល្យ រឺង បច្ចេកទេសផ្សេងទៀត ដែលបានបណ្តុះបណ្តាល និងបំរើការនៅតាមគ្រឹះស្ថានសិក្សាសាធារណៈមធ្យមសិក្សាចំណេះទូទៅ មធ្យមសិក្សាបច្ចេកទេស ឧត្តមសិក្សា និងអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុង នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកិរិតឧត្តមមានមុខងារក្នុងតំណែងជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវ និងមុខងារក្នុងតំណែងគ្រប់គ្រង ។

## ជំពូក ទី ២
## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកិរិតឧត្តម មាន ៣ ឋានន្តរស័ក្តិ ÷

- ឋានន្តរស័ក្តិ ទី ១ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកិរិតឧត្តម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ទី ២ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកិរិតឧត្តម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិ ទី ៣ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកិរិតឧត្តម មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

គ្រូបង្រៀនកិរិតឧត្តមមានឧបនិស្ស័យអាចកាន់មុខតំណែងគ្រប់គ្រងរួមជាមួយនឹងមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅតាមគ្រឹះស្ថានសិក្សា និង អង្គភាពជំនាញនានា ដូចខាងក្រោម ÷

ឋានន្តរស័ក្តិទី ១ - សាកលវិទ្យាធិការ អគ្គនាយក អគ្គាធិការ

ឋានន្តរស័ក្តិទី ២ - សាកលវិទ្យាធិការរង ព្រឹទ្ធបុរសមហាវិទ្យាល័យ អគ្គនាយករង ៧.ក.

អគ្គាធិការរង អធិការ ប្រធាននាយកដ្ឋាន

ឋានន្តរស័ក្តិទី ៣ - ព្រឹទ្ធបុរសរង មហាវិទ្យាល័យ

- អនុប្រធាននាយកដ្ឋាន
- ប្រធានមន្ទីរ ខេត្ត ក្រុង
- អធិការរង
- នាយកមជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ
- នាយកសាលាគរុកោសល្យខេត្ត ក្រុង
- នាយកវិទ្យាល័យ

និង មុខតំណែងឯទៀតដែល មានថ្នាក់ស្មើនឹងមុខតំណែងខាងលើ នៃឋានន្តរស័ក្តិនីមួយៗនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៣
## ការជ្រើសរើស

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជន ជានិស្សិត ឬ និង ជាមន្ត្រីរាជការ របស់ក្រសួងអប់រំ យុវជន និង កីឡា និងមន្ត្រីរាជការផ្សេងទៀត ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជានិស្សិត ឬនិងសំរាប់បេក្ខជនជាមន្ត្រីរាជការត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ .-**

ការប្រលងជ្រើសរើសក្នុងចំណោម និស្សិត ត្រូវបើកទូលាយ ចំពោះបេក្ខជនដែលមានអាយុ ច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយមាន សញ្ញាប័ត្រទាបបំផុត បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌ ក្នុងការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ គ្រូបង្រៀនកំរិតឧត្តមសំរាប់បេក្ខជនជាមន្ត្រីរាជការត្រូវកំណត់ដោយក្រសួង អប់រំ យុវជន និង កីឡា ។

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិតត្រូវឆ្លងកាត់ការពិនិត្យសុខភាព និងកាយសម្បទា មុននឹងចូលសាលាបណ្តុះបណ្តាល ។ការពិនិត្យសុខភាព និងកាយសម្បទា លើកទី ២ ត្រូវអនុវត្តមុនធ្វើការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

លក្ខណៈវិនិច្ឆ័យកាយសម្បទា ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។ល។

## ជំពូក ទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិត និង ក្នុងចំណោមមន្ត្រីរាជការ មានឋានៈ ជាគរុ និស្សិតកីឡាឧត្តម ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូង ដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង គរុនិស្សិតកីឡាឧត្តម ដែលប្រលងជាប់ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាម ខេត្ត ក្រុង ឬ នៅថ្នាក់កណ្តាល ផ្អែកលើលទ្ធផលប្រលងបញ្ចប់ការបណ្តុះបណ្តាលហើយត្រូវបានតែងតាំងជាគ្រូបង្រៀនកីឡាឧត្តមកម្មសិក្សា តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ។

គ្រូបង្រៀនកីឡាឧត្តមកម្មសិក្សា ដែលបានជ្រើសរើសចេញពី និស្សិតត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេល ១២ខែ ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលត្រូវបានជ្រើសរើសចេញពីនិស្សិត ត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ ទី ៣ ។

គ្រូបង្រៀនកីឡាឧត្តម ដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ របស់ ក្រសួងអប់រំ យុវជន និង កីឡា ពុំចាំបាច់ឆ្លងកាត់ កម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះត្រូវបាន តាំងស៊ប់ ក្នុងឋានន្តរស័ក្តិទី ៣ ព្រមទាំងត្រូវបានទទួលសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ ចាស់របស់ខ្លួន ។

គ្រូបង្រៀនកីឡាឧត្តមដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ផ្សេងៗទៀត ត្រូវធ្វើ កម្មសិក្សាសាកល្បងរយៈ ពេល ៦ ខែ ដោយទទួលសន្ទស្សន៍ បៀវត្ស ខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ ចាស់ របស់ខ្លួន ។ ក្រោយពេលធ្វើកម្មសិក្សា សាកល្បង មន្ត្រី ទាំងនេះត្រូវបានតាំងស៊ប់ ក្នុងឋានន្តរស័ក្តិទី ៣ និង ត្រូវទទួលបៀវត្ស តាមសន្ទស្សន៍ ដែលបានរៀបមកហើយ ។

គ្រូបង្រៀនកីឡាឧត្តមកម្មសិក្សាដែល ធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការត្រូវអនុញ្ញាតអោយបន្តកម្មសិក្សានៅឆ្នាំទី ២ ទៀត ។ ក្នុងករណី ធ្លាក់កម្មសិក្សានៅឆ្នាំ ទី ២ នេះ កម្មសិក្សាការីជ្រើសរើស ចេញមកពីនិស្សិតត្រូវលុបឈ្មោះចោល កម្មសិក្សាការី ជ្រើសរើសចេញ មកពីមន្ត្រីរាជការ ត្រូវ បញ្ជូនទៅ ក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេល ចូលសាលាបណ្តុះបណ្តាលសំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកីឡាឧត្តម ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។ល។

## ជំពូក ទី ៥
## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ គ្រូបង្រៀនកំរិតឧត្តមត្រូវបានតែងតាំងអោយបំពេញមុខងារក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា ៣ ឬ អាចត្រូវបានតែងតាំង ក្នុងមុខតំណែងគ្រប់គ្រងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ក្នុងមាត្រា ១៤ និង មាត្រាបន្តបន្ទាប់ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូក ទី ៦
## ការដាក់អោយស្ថិតនៅក្រៅក្របខណ្ឌដើម

**មាត្រា ១១ .-**

គ្រូបង្រៀនកំរិតឧត្តមអាចត្រូវបានដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែង ដើម្បីបំរើការនៅក្រសួងស្ថាប័នមួយផ្សេងទៀតតាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូក ទី ៧
## ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិ

**មាត្រា ១២ .-**

គ្រូបង្រៀនកំរិតឧត្តម ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រា បន្តបន្ទាប់ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ÷

-គំនិតផ្តួចផ្តើម ច្នៃប្រឌិត និងលទ្ធផលការងារ

-មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ វិន័យការងារ

- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ

- សាមគ្គីភាព សីលធម៌រស់នៅ សកម្មភាពសង្គម ។

ការតម្លើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ ក្នុងវេនជ្រើសរើស និង ១ ភាគ ៤ តាមវេន អតីតភាព ។

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតឧត្តម ដើមខ្សែពិសេស ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។ ល.រ.

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ដើមខ្សែ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ត្រូវសំរេចដោយប្រកាស របស់ ក្រសួង អប់រំ យុវជន និង កីឡា។

**មាត្រា ១៣ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ តាមធម្មតាត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណី ចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមុយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តតាមគោលការណ៍ ចំនួនមុខតំណែងគ្រប់គ្រងដែលមានទំនេរ ឬ គោលការណ៍ ភាគរយ ។ គោលការណ៍ភាគរយត្រូវបានកំណត់ ៧០% សំរាប់ឋានន្តរស័ក្តិទី ៣ ២៥% សំរាប់ឋានន្តរស័ក្តិទី ២ និង ៥% សំរាប់ឋានន្តរស័ក្តិ ទី ១។

ការតម្លើងឋានន្តរស័ក្តិនេះ ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិនិងការវាយតំលៃ របស់ ឋានានុក្រម គ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាល និង វិក្រឹតការជំនាញ រយៈពេលវែង នៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិពីគ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ ទៅ ឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែពិសេសត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

ការតម្លើងពីឋានន្តរស័ក្តិគ្រូបង្រៀនកិត្តិឧត្តមទៅឋានន្តរស័ក្តិគ្រូបង្រៀនកិត្តិឧត្តមដើមខ្សែត្រូវសំរេចដោយអនុក្រឹត្យ ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ គឺ គ្រូបង្រៀនកិត្តិឧត្តមទាំងឡាយដែលបានឡើងដល់ថ្នាក់ លេខ ១១ ឡើងទៅ ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌ គ្រូបង្រៀនកិត្តិឧត្តម ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ ពិសេស គឺ គ្រូបង្រៀនកិត្តិឧត្តមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ ឡើងទៅ នៃឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ដើមខ្សែ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌគ្រូបង្រៀនកិត្តិឧត្តម និង តំលៃឯកតានៃសន្ទស្សន៍ ព្រមទាំងកិត្តិយសាភការ ផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។/ស.

## ជំពូក ទី ៤
## ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិសំរាប់កាន់មុខតំណែង
## ជារអធិការមធ្យមសិក្សា

**មាត្រា ១៦ .-**

អធិការមធ្យមសិក្សា ជាមន្ត្រីបច្ចេកទេសអធិការកិច្ច ដែលបានបណ្តុះបណ្តាល សំរាប់មធ្យមសិក្សាចំណេះទូទៅ បំរើការនៅថ្នាក់កណ្តាល និងខេត្ត ក្រុង ។

**មាត្រា ១៧ .-**

អធិការមធ្យមសិក្សាត្រូវបានជ្រើសរើសតាមការប្រលងជ្រើសរើស ក្នុងចំណោមមន្ត្រីរាជការជាគ្រូបង្រៀនកំរិតឧត្តមកំពុងបំរើការក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់ការប្រលងនីមួយៗ ត្រូវកំណត់ឡើងដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

លក្ខខណ្ឌនៃការប្រលងជ្រើសរើសមាន ÷

- ថ្នាក់លេខ ១១ ឡើងទៅ នៃ ឋានន្តរស័ក្តិគ្រូបង្រៀនកំរិតឧត្តម
- អាយុ យ៉ាងច្រើន ៤៥ ឆ្នាំ ។

**មាត្រា ១៨ .-**

បេក្ខជនដែលបានប្រលងជាប់ក្នុងការប្រលងជ្រើសរើស មានឋានៈ ជាគរុនិស្សិតអធិការមធ្យមសិក្សា ហើយត្រូវទទួលការបណ្តុះបណ្តាល ការងារអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា ។

បន្ទាប់ពីការបណ្តុះបណ្តាល គរុនិស្សិតអធិការមធ្យមសិក្សាដែលប្រលងជាប់ជាអធិការមធ្យមសិក្សាត្រូវបានតម្លើង ទៅក្នុងឋានន្តរស័ក្តិ ទី ២ ដោយអនុក្រឹត្យ ហើយត្រូវបានទទួល សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់ខ្លួននិងត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ បន្ថែមជាស្វ័យប្រវត្តិ ។ អធិការមធ្យមសិក្សាត្រូវបានបែងចែកអោយទៅបំរើការនៅថ្នាក់កណ្តាល ឬ ខេត្ត ក្រុង តាមប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៩ .-**

អធិការមធ្យមសិក្សា ត្រូវទទួលប្រាក់រង្វាន់មុខតំណែងអធិការ ។

**មាត្រា ២០ .-**

ក្រៅពីគោលការណ៍ដែលមានកំណត់ក្នុងមាត្រា ១៧-១៨ និង ១៩ ខាងលើ អធិការមធ្យមសិក្សាត្រូវអនុវត្តគោលការណ៍ផ្សេងៗទៀត ដូចគ្រូបង្រៀនកំរិតឧត្តម ។ល។

**មាត្រា ២១ .-**

ចំនួនដំបូង នៃអធិការមធ្យមសិក្សា ត្រូវកសាងចេញពីអធិការមធ្យមសិក្សាទាំងអស់ ដែលបច្ចុប្បន្ន កំពុងបំពេញមុខតំណែងពិតប្រាកដជាអធិការមធ្យមសិក្សា នៅក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២២ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកិត្តិឧត្តម ត្រូវទទួលប្រាក់កំរៃគរុកោសល្យ ជាប្រាក់រង្វាន់ នៃមុខតំណែងគ្រូបង្រៀន ។

**មាត្រា ២៣ .-**

គ្រូបង្រៀនកិត្តិឧត្តម បំរើការរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែពិសេសត្រូវសំរេច ដោយព្រះរាជក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ ត្រូវសំរេចដោយ អនុក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកិត្តិឧត្តមត្រូវសំរេចដោយប្រកាសរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២៤ .-**

គ្រូបង្រៀនកិត្តិឧត្តម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលបន្តរយៈ ពេលសរុបយ៉ាងតិច ១ឆ្នាំ នៅក្នុងជំនាញដែលបំរើអោយវិស័យអប់រំ យុវជន និង កីឡា ដោយមានវិញ្ញាបនប័ត្រ ឬ លិខិតបញ្ជាក់ការសិក្សាត្រូវបានទទួលការតម្លើងថ្នាក់ ១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

ចំពោះគ្រូបង្រៀនកិត្តិឧត្តម ដែលត្រូវបានក្រសួងចាត់អោយទៅបន្តការសិក្សា ឬ បំប៉នជំនាញ ផ្សេងៗ រយៈពេលសិក្សានោះ ត្រូវបានគិតសំរាប់ការតម្លើងឋានន្តរស័ក្តិ ឬ ឡើងថ្នាក់ ។

**មាត្រា ២៥ .-**

ពេលចូលបំរើការដំបូង ឬក្នុងពេលបំរើការ គ្រូបង្រៀនកិត្តិឧត្តម ដែលមានសញ្ញាប័ត្រខ្ពស់ជាង បរិញ្ញាប័ត្រត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិ ១ ថ្នាក់ សំរាប់បរិញ្ញាប័ត្រជាន់ខ្ពស់ និង ២ថ្នាក់ សំរាប់សញ្ញាប័ត្រ ក្រោយបរិញ្ញាប័ត្រជាន់ខ្ពស់ ដោយមានការទទួលស្គាល់ ពីគណៈកម្មាធិការពិនិត្យ និងវាយតំលៃកិតសញ្ញាប័ត្រ ។ល។

និង លិខិតបញ្ជាក់ការសិក្សា ។

មាត្រា ២៦ .-

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់គ្រូបង្រៀនកំរិតឧត្តមត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូក ទី ១០

## អន្តរប្បញ្ញត្តិ

មាត្រា ២៧ .-

ចំនួនដំបូង នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តមត្រូវកសាងចេញពីសមាហរណកម្ម មន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបំពេញ មុខតំណែង និង មុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងគ្រឹះស្ថានសិក្សាគ្រប់កំរិត និងក្នុងអង្គភាពជំនាញ ថ្នាក់កណ្តាល និងតាម ខេត្ត ក្រុង របស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ២៨ .-

មុខតំណែងគ្រប់គ្រងនីមួយៗ ដែលត្រូវអនុវត្តតាមគោលការណ៍ក្របខ័ណ្ឌ ឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់ជាងគេ មិនមានប្រតិកម្ម ទៅលើមុខតំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយ លើកលែងតែមានការចាំបាច់ដែលជា សមត្ថកិច្ច របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ២៩ .-

ក្នុងពេលប្រភពបេក្ខជនបរិញ្ញាប័ត្រខាងភាសាបរទេស មានចំនួនមិនទាន់គ្រប់គ្រាន់ការប្រលងជ្រើសរើស គ្រូបង្រៀនកំរិតឧត្តម ផ្នែកភាសាបរទេសត្រូវធ្វើឡើងក្នុងចំណោមបេក្ខជនជាសិស្សមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិដែលមាន អាយុ ច្រើនបំផុត ២៥ ឆ្នាំហើយទទួលការបណ្តុះបណ្តាល យកបរិញ្ញាប័ត្រអប់រំដើម្បីតែងតាំងជា គ្រូបង្រៀនកំរិតឧត្តមកម្មសិក្សា ។

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលមុននឹងធ្វើការប្រលងជ្រើសរើស ។

## ជំពូក ទី ១១

## អវសានប្បញ្ញត្តិ

មាត្រា ៣០ .-

បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣១ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣២ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

លេខ: ១៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៤១

## ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន

យើង

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១ ។

## ត្រាស់បង្គាប់

### ជំពូក ទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌ គ្រូបង្រៀនកំរិតមូលដ្ឋាន ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចមានចែងក្នុង មាត្រា៤ នៃព្រះរាជក្រឹត្យលេខ ជស-រកត ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំ មុខងារសាធារណៈ របស់រដ្ឋ។

**មាត្រា ២ .-**

ក្របខ័ណ្ឌ គ្រូបង្រៀនកំរិតមូលដ្ឋាន ស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា ប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេស ខាងគរុកោសល្យ និងបច្ចេកទេសផ្សេងៗទៀត ដែលបាន បង្ហាត់បង្រៀន និងបំរើការនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាបច្ចេកទេស និងអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុង នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន មានមុខងារក្នុងតំណែងជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវ និង មុខងារក្នុងតំណែងគ្រប់គ្រង។

### ជំពូក ទី ២
### ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន មាន ៣ ឋានន្តរស័ក្តិ ÷

- ឋានន្តរស័ក្តិ ទី ១ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតមូលដ្ឋាន ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ទី ២ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតមូលដ្ឋាន ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិ ទី ៣ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតមូលដ្ឋាន មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

គ្រូបង្រៀនកំរិតមូលដ្ឋាន មានឧបនិស្ស័យអាចកាន់មុខតំណែងគ្រប់គ្រងរួមជាមួយនឹងមន្ត្រីក្របខ័ណ្ឌក្រមការ ទៅតាមគ្រឹះស្ថានសិក្សា និង អង្គភាពជំនាញនានាដូច ខាងក្រោម ÷ ./.

ឋានន្តរស័ក្តិទី ១ - ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល
- អនុប្រធានមន្ទីរខេត្ត ក្រុង

ឋានន្តរស័ក្តិទី ២ - អនុប្រធានការិយាល័យ ក្នុងរដ្ឋបាលកណ្តាល
- ប្រធានការិយាល័យ នៃមន្ទីរខេត្ត ក្រុង

ឋានន្តរស័ក្តិ ទី ៣ - អនុប្រធានការិយាល័យ នៃមន្ទីរខេត្ត ក្រុង
-ប្រធានការិយាល័យស្រុកខណ្ឌ
-នាយកអនុវិទ្យាល័យ
-នាយកសាលាបឋមសិក្សា
-នាយកសាលាមត្តេយ្យសិក្សា

និង មុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ នៃឋានន្តរស័ក្តិនីមួយៗ នៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៣
## ការជ្រើសរើស

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត ឬ និង ជាមន្ត្រីរាជការរបស់ ក្រសួងអប់រំ យុវជន និង កីឡា និងមន្ត្រីរាជការផ្សេងទៀត ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជន ជាសិស្សនិស្សិត ឬ និង បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់ឡើងដោយ រាជរដ្ឋាភិបាល តាមសំណើរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ .-**

ការប្រលងជ្រើសរើសក្នុងចំណោមសិស្សនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រទាបបំផុត សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រសមមូល ។ អាយុនេះអាចរំកិលពី ២៥ ដល់ ៣០ ឆ្នាំស្របតាមមាត្រា១១នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ លក្ខខណ្ឌក្នុងការប្រលងជ្រើសរើស ចូលក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋានសំរាប់បេក្ខជនជាមន្ត្រីរាជការត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា។

ការប្រលងជ្រើសរើសក្នុងចំណោមសិស្ស និស្សិតត្រូវឆ្លងកាត់ការពិនិត្យសុខភាព និងកាយសម្បទា មុននឹងចូលរៀននៅសាលា បណ្តុះបណ្តាល ។ ការពិនិត្យសុខភាព និងកាយសម្បទាលើកទី២ ត្រូវអនុវត្តមុនធ្វើការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។ល។

លក្ខណៈវិនិច្ឆ័យកាយសម្បទា ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

## ជំពូក ទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមសិស្សនិស្សិតមានឋានៈជាគរុសិស្សកំរិតមូលដ្ឋាន ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងយ៉ាងតិច២ឆ្នាំដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

ចំពោះអ្នកដែលមានសញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេស ឬសញ្ញាប័ត្រសមមូល ការបណ្តុះបណ្តាលដំបូងមានរយៈពេលយ៉ាងតិច ១ ឆ្នាំ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង គ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវបានបែងចែក អោយទៅបំរើការងារនៅតាមខេត្ត ក្រុង ឬ នៅថ្នាក់កណ្តាល ផ្អែកលើលទ្ធផលប្រលងបញ្ចប់ការបណ្តុះបណ្តាល ហើយត្រូវបានតែងតាំងជាគ្រូបង្រៀនកំរិតមូលដ្ឋាន កម្មសិក្សាតាមប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ។

គ្រូបង្រៀនកំរិតមូលដ្ឋានដែលជ្រើសរើសចេញពីសិស្ស និស្សិតត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេល ១២ ខែ ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលត្រូវបានជ្រើសរើសចេញពីសិស្សនិស្សិតត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ ទី ៣ ។

គ្រូបង្រៀនកំរិតមូលដ្ឋានដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ នៃក្រសួងអប់រំ យុវជន និងកីឡា ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីរាជការទាំងនេះត្រូវបាន តាំងស៊ប់ ក្នុងឋានន្តរស័ក្តិទី ៣ ព្រមទាំងត្រូវបានទទួលសន្ទស្សន៍បៀវត្ស ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ ចាស់របស់ខ្លួន ។

គ្រូបង្រៀនកំរិតមូលដ្ឋានដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការផ្សេងៗត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ៦ ខែ ដោយទទួលសន្ទស្សន៍ បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់ខ្លួន ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិ ទី ៣ នៃគ្រូបង្រៀនកំរិតមូលដ្ឋាន និងត្រូវទទួលបៀវត្សតាមសន្ទស្សន៍ដែលបានរៀបមកហើយ ។

គ្រូបង្រៀនកំរិតមូលដ្ឋានដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការត្រូវអនុញ្ញាតអោយបន្តកម្មសិក្សានៅឆ្នាំទី ២ទៀត ។ ក្នុងករណីធ្លាក់កម្មសិក្សានៅឆ្នាំទី ២ នេះ កម្មសិក្សាការី ជ្រើសរើសចេញមកពីសិស្សនិស្សិត ត្រូវលុបឈ្មោះចោល កម្មសិក្សាការី ជ្រើសរើសចេញមកពីមន្ត្រីរាជការ ត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលចូលសាលាបណ្តុះបណ្តាលសំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃគ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវធ្វើឡើងដោយ អនុក្រឹត្យ ។៚.

## ជំពូក ទី ៥

## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ រួចហើយ គ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវបានតែងតាំងអោយបំពេញមុខងារក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា ៣ ឬ អាចត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រងទំនេរ ណាមួយ ដូចមានចែងក្នុងមាត្រា ៥ ខាងលើស្របតាមបំនងនិងសមត្ថភាពរបស់ខ្លួន តាមបែបបទ ដូចមានកំណត់ក្នុងមាត្រា ១៤ និង មាត្រាបន្តបន្ទាប់ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូក ទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១ .-**

គ្រូបង្រៀនកំរិតមូលដ្ឋាន អាចត្រូវបានដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីបំរើការនៅក្រសួងស្ថាប័ន មួយផ្សេងទៀតតាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូក ទី ៧

## ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិ

**មាត្រា ១២ .-**

គ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ÷

- គំនិតផ្តួចផ្តើម ថ្វៃប្រឌិត និង លទ្ធផលការងារ
- មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ វិន័យការងារ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីភាព សីលធម៌រស់នៅ សកម្មភាពសង្គម ។

ការតម្លើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ ក្នុងវេនជ្រើសរើស និង ១ ភាគ ៤ តាមវេន អតីតភាព ។

**មាត្រា ១៣ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ តាមធម្មតាត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណី ចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់ ៸.។.

ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់ការប្រលងនីមួយៗ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។

លក្ខខណ្ឌនៃការប្រលងជ្រើសរើសមាន :

-ថ្នាក់លេខ ១១ ឡើងទៅ នៃឋានន្តរស័ក្តិគ្រូបង្រៀនកំរិតមូលដ្ឋាន

-អាយុយ៉ាងច្រើន ៤៥ ឆ្នាំ ។

**មាត្រា ១៨ .-**

បេក្ខជនដែលបានប្រលងជាប់ក្នុងការប្រលងជ្រើសរើស មានឋានៈ ជាគរុសិស្ស អធិការបឋមសិក្សា ហើយត្រូវទទួលការបណ្តុះបណ្តាល ការងារអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា ។

បន្ទាប់ពីការបណ្តុះបណ្តាល គរុសិស្សអធិការបឋមសិក្សាដែលប្រលងជាប់ជាអធិការបឋមសិក្សា ត្រូវបានតម្លើងទៅក្នុងឋានន្តរស័ក្តិ ទី ២ ដោយប្រកាស ហើយត្រូវបានទទួល សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពី សន្ទស្សន៍ចាស់របស់ខ្លួន និងត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់បន្ថែមជាស្វ័យប្រវត្តិ ។ អធិការបឋមសិក្សាត្រូវបានបែងចែក អោយទៅបំរើការ នៅថ្នាក់ការិយាល័យ ខណ្ឌ ស្រុក ខេត្ត ក្រុង តាមប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៩ .-**

អធិការបឋមសិក្សា ត្រូវទទួលប្រាក់រង្វាន់មុខតំណែងអធិការ ។

**មាត្រា ២០ .-**

ក្រៅពីគោលការណ៍ ដែលមានកំណត់ក្នុងមាត្រាទី ១៧-១៨ និង១៩ ខាងលើ អធិការបឋមសិក្សា អនុវត្តគោលការណ៍ផ្សេងៗ ទៀត ដូចគ្រូបង្រៀនកំរិតមូលដ្ឋាន ។

**មាត្រា ២១ .-**

ចំនួនដំបូង នៃអធិការបឋមសិក្សាត្រូវកសាងចេញពីអធិការបឋមសិក្សា ទាំងអស់ ដែលបច្ចុប្បន្ន កំពុងបំពេញ មុខតំណែងពិតប្រាកដជាអធិការបឋមសិក្សា នៅក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២២ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវទទួលប្រាក់កំរៃគរុកោសល្យ ជាប្រាក់រង្វាន់ នៃមុខតំណែងគ្រូបង្រៀន ។ ៧.ក.

ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់ការប្រលងនីមួយៗ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។

លក្ខខណ្ឌនៃការប្រលងជ្រើសរើសមាន :

-ថ្នាក់លេខ ១១ ឡើងទៅ នៃឋានន្តរស័ក្តិគ្រូបង្រៀនកំរិតមូលដ្ឋាន

-អាយុយ៉ាងច្រើន ៤៥ ឆ្នាំ ។

**មាត្រា ១៨ .-**

បេក្ខជនដែលបានប្រលងជាប់ក្នុងការប្រលងជ្រើសរើស មានឋានៈ ជាគរុសិស្ស អធិការបឋមសិក្សា ហើយត្រូវទទួលការបណ្តុះបណ្តាល ការងារអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា ។

បន្ទាប់ពីការបណ្តុះបណ្តាល គរុសិស្សអធិការបឋមសិក្សាដែលប្រលងជាប់ជាអធិការបឋមសិក្សា ត្រូវបានតម្លើងទៅក្នុងឋានន្តរស័ក្តិ ទី ២ ដោយប្រកាស ហើយត្រូវបានទទួល សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពី សន្ទស្សន៍ចាស់របស់ខ្លួន និងត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់បន្ថែមជាស្វ័យប្រវត្តិ ។ អធិការបឋមសិក្សាត្រូវបានបែងចែក អោយទៅបំរើការ នៅថ្នាក់កណ្តាល ឬ ខេត្ត ក្រុង តាមប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៩ .-**

អធិការបឋមសិក្សា ត្រូវទទួលប្រាក់រង្វាន់មុខតំណែងអធិការ ។

**មាត្រា ២០ .-**

ក្រៅពីគោលការណ៍ ដែលមានកំណត់ក្នុងមាត្រាទី ១៧-១៨ និង១៩ ខាងលើ អធិការបឋមសិក្សា អនុវត្តគោលការណ៍ផ្សេងៗ ទៀត ដូចគ្រូបង្រៀនកំរិតមូលដ្ឋាន ។

**មាត្រា ២១ .-**

ចំនួនដំបូង នៃអធិការបឋមសិក្សាត្រូវកសាងចេញពីអធិការបឋមសិក្សា ទាំងអស់ ដែលបច្ចុប្បន្ន កំពុងបំពេញ មុខតំណែងពិតប្រាកដជាអធិការបឋមសិក្សា នៅក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២២ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវទទួលប្រាក់កំរៃគរុកោសល្យ ជាប្រាក់រង្វាន់ នៃមុខតំណែងគ្រូបង្រៀន ។៚

មាត្រា ២៣ .-

គ្រូបង្រៀនកំរិតមូលដ្ឋាន បំរើការរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ការដាក់អោយចូលនិវត្តន៍ត្រូវ សំរេចដោយប្រកាសរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ២៤ .-

គ្រូបង្រៀនកំរិតមូលដ្ឋានដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលបន្ត រយៈពេលសរុបយ៉ាងតិច ១ ឆ្នាំ នៅក្នុងជំនាញដែលបំរើអោយវិស័យអប់រំ យុវជន និង កីឡាដោយមានវិញ្ញាបនប័ត្រ ឬ លិខិតបញ្ជាក់ការសិក្សា ត្រូវបានទទួលការតម្លើងថ្នាក់ ១ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនស្រែរើស ។

ចំពោះគ្រូបង្រៀនកំរិតមូលដ្ឋានដែលត្រូវបានក្រសួងចាត់អោយទៅបន្តការសិក្សា ឬ បំប៉នជំនាញផ្សេងៗ រយៈពេលសិក្សានោះ ត្រូវបានគិតសំរាប់ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ ។

មាត្រា ២៥ .-

ពេលចូលបំរើការដំបូង ឬ ក្នុងពេលបំរើការ គ្រូបង្រៀនកំរិតមូលដ្ឋានដែលមានបរិញ្ញាប័ត្រឡើងទៅ ឬ សញ្ញាប័ត្រសមមូល ត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ២៦ .-

សញ្ញាស័ក្តិ និង ឯកសណ្ឋានសំរាប់គ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូក ទី ១០
## អន្តរប្បញ្ញត្តិ

មាត្រា ២៧ .-

ចំនួនដំបូង នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ត្រូវកសាងចេញពីសមាហរណកម្ម មន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និង មុខងារពិតប្រាកដរបស់ ក្របខ័ណ្ឌក្នុងគ្រឹះស្ថានសិក្សា និងអង្គភាពជំនាញនានា នៅថ្នាក់កណ្តាល និង ខេត្ត ក្រុង ។

មាត្រា ២៨ .-

មុខតំណែងគ្រប់គ្រងនីមួយៗ ដែលត្រូវអនុវត្តតាមគោលការណ៍ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាងគេមិនមានប្រតិកម្ម ទៅលើមុខតំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយ លើកលែងតែមានការចាំបាច់ ដែលជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និង កីឡា ។ ...

## ជំពូក ទី ១១
## អវសានប្បញ្ញត្តិ

មាត្រា ២៩ .-

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣០ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣១ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខៈ ១៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៨២

## ស្តីពី
## របបសញ្ញារដ្ឋបាល សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
## នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

## យើង

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៣៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១ ។

# ត្រាស់បង្គាប់

## ជំពូក ទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា១ .—

ត្រូវបានបង្កើតរូបសញ្ញារដ្ឋបាល សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការដែលបំរើការងារតាមក្រសួងស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២ .—

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សំរាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូក ទី ២
## រូបសញ្ញារដ្ឋបាល

មាត្រា៣ .—

រូបសញ្ញារដ្ឋបាលនេះត្រូវបានកំណត់ដូចតទៅ ÷

-មានរាងពងក្រពើ

-នៅខាងក្រោមចំកណ្តាល មានក្បាច់អង្គរ និងមានសន្លឹកភ្ញីទេសពីរជួរ រាងជាស្នែងក្របីទ្រជើងពាន

-មានជើងពានមួយទ្រសៀវភៅច្បាប់ បើកចំពាក់កណ្តាលនៅពីលើសន្លឹកភ្ញីទេស

-លើសៀវភៅច្បាប់បើកចំពាក់កណ្តាលនេះ មានមកុដរាជ្យ និងនៅលើមកុដរាជ្យ មានកាំរស្មីចំនួន ២៥ កាំ ។

រូបសញ្ញារដ្ឋបាលនេះ សំរាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិចុងកអាវនៃមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ និងដាក់នៅលើស័ក្តិខ្ទាស់លើអាវបុរស ឬលើក្រមាពាក់នារបស់នារី ដែលជាមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

រូបសញ្ញារដ្ឋបាលនេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី ១ ។

## ជំពូក ទី ៣
## សញ្ញាស័ក្តិ

មាត្រា៤ .—

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចតទៅ ÷

ក. ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៗ

១-អំពីស័ក្តិស្នារ

ស័ក្តិស្នាមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កូរស្រូវពណ៌មាស និងក្បាច់សន្ទឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនេះ មានរូបសញ្ញារដ្ឋបាលពណ៌មាស និងនៅពីលើខាងរូបសញ្ញារដ្ឋបាល មានឡេវរូបព្រះសង្ខារពណ៌មាសមួយ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញក្ដារឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញត្រីនេះ មានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាសបីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ខ្នាតស័ក្តិស្នាត្រូវបានកំណត់ដូចខាងក្រោម ÷

-បាតក្រោម ប្រវែង ៦ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្ដោយពីលើដល់បាតក្រោម ប្រវែង ១៣ សង្ទីម៉ែត្រ

២-អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កូរស្រូវពណ៌មាស និងក្បាច់សន្ទឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញារដ្ឋបាលពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងជាប្រលេឡូក្រាម

-បណ្ដោយ ប្រវែង ៩ សង្ទីម៉ែត្រ

-ទទឹង ប្រវែង ៣.៨ សង្ទីម៉ែត្រ

៣-អំពីស័ក្តិចុងដៃអាវទាំងសងខាង

ស័ក្តិចុងដៃអាវ មានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានក្បាច់កូរស្រូវពណ៌មាសមួយនៅខាងចុង ហើយក្បាច់កូរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញត្រីពណ៌មាសនៅជាយផ្នែកខាងលើ និងផ្នែកសងខាង ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញត្រីនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយខ្សែ ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងបួនជ្រុងទ្រវែង

-បណ្ដោយ ប្រវែង ៣២ សង្ទីម៉ែត្រ ៩.៣ .

-ទទឹង ប្រវែង ៩ សង្ទីម៉ែត្រ

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសំរាប់មន្ត្រី ÷

-ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៣

-ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសំរាប់នារី មានទំហំដូចខាងក្រោមនេះ ÷

-ចំពោះស័ក្តិស្មា អាចមានទំហំ ៨០ ៕ ៨៥ ៕ ៩០ ៕ នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

-ស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០ ៕ ទៅ ៧៥ ៕ នៃទំហំទទឹងស័ក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី

-ស័ក្តិកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើកំពស់ករបស់នារី ។

៤. អំពីស័ក្តិខ្ពស់លើអាវសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

ស័ក្តិខ្ពស់លើអាវសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានរាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និងកំពូលរាងជ្រលម កំពស់ ៦០ សង្ទីម៉ែត្រ ទទឹង ៤០ សង្ទីម៉ែត្រ ។ ផ្នែកខាងក្នុងមានរូបសញ្ញារដ្ឋបាលពណ៌មាស បន្ទាប់មកមានក្បាច់ផ្ញេញក្របិពហ៍មាសមួយព័ទ្ធអមផង ។ ផ្នែកខាងក្រៅមានខ្សែពួរវេញព័ទ្ធអមពណ៌មាសបីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ស័ក្តិខ្ពស់លើអាវនេះ សំរាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សំរាប់ខ្ទាស់លើក្រមាពាក់នារី ក្នុងឯកសណ្ឋានប្រពៃណី ។

រូបគំនូរស័ក្តិខ្ពស់លើអាវ និងលើក្រមាពាក់សំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

ខ. ក្របខ័ណ្ឌមន្ត្រីក្រមការ

សញ្ញាស័ក្តិសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិ ដូចសញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសំរាប់ក្របខ័ណ្ឌមន្ត្រីក្រមការមានពណ៌ប្រាក់ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសំរាប់មន្ត្រី ÷

-ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី ៦

-ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៧

-និងឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។/.

## ជំពូកទី ៤
## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា៥ —**

ប្រភេទឯកសណ្ឋានសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម ÷

### ក‸ឯកសណ្ឋានផ្លូវការ

#### ១‸ចំពោះបុរស

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ នៅចុងដៃអាវទាំងសងខាងមានឡេវបញ្ចោត ៣ រូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះមានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។

-ខោជើងវែងមានពណ៌ទឹកប៊ិចក្រម៉ៅ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

#### ២‸ចំពោះស្ត្រី

-អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង អាវដៃវែងត្រឹមភ្នែកគោលដៃ គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន ៥ ។ ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ គ្មានហោប៉ៅ ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិ ។

-សំពត់សំឡុយអំពីអន្លូញ មានឆ្នូតពណ៌ខៀវ និងពណ៌ខ្មៅ ដែលឆ្នូតនីមួយៗ មានទំហំ ១.៥ មីល្លីម៉ែត្រ មានសំរុងលើភ្នែកគោលនៃស្មងជើង ប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់ ។

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ឬពណ៌ខ្មៅសំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់បុរស និងស្ត្រីមានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

### ខ‸ឯកសណ្ឋានប្រពៃណីជាតិ

#### ១‸ចំពោះបុរស

-អាវកុដពណ៌ស កត្រង់ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំង ៧៖.

បូននោះ មានឡេវរូបព្រះសង្ខារពណ៌មាស ។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ចោត ៣ រូបព្រះសង្ខារពណ៌មាស ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ខារចំនួន ៧ ពណ៌មាស ។

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-ស្បែកជើងឃ្លុប ពណ៌ខ្មៅ កខ្លី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

## ២-ចំពោះស្ត្រី

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវពណ៌ស មានកមូល ដៃវែង និងមានស័ក្តិនៅចុងដៃអាវ

-ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីទ្រូន (១) តាមពិធីការកំណត់

-នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានខ្ទាស់សញ្ញាសំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ឬពណ៌ខ្មៅសំរាប់ពេលល្ងាច

-កាបូបយួរដៃពណ៌ស ឬពណ៌ខ្មៅ ( មិនអោយស្ពាយទេ ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់បុរស និងស្ត្រីដែលស្លៀកសំពត់ផាមួងចងក្បិន មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៦ .—**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការសំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

-ចំពោះឯកសណ្ឋានប្រពៃណីជាតិសំរាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ ត្រូវបានកំណត់អោយប្រើឯកសណ្ឋាននេះ តែមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែលមានឋានន្តរស័ក្តិជាឧត្តមមន្ត្រី ។

## ជំពូកទី ៥
## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

**មាត្រា៧ .—**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ សញ្ញាស័ក្តិ និងសំភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ មួយសំរាប់ សំរាប់ប្រើប្រាស់រយៈពេល បី ឆ្នាំម្តង ។ ល.ក.

(១) ពណ៌ស៊ីទ្រូន : សម្បុរសលាយលឿងខ្ចីបន្តិច ។ សម្បុរសលឿងខ្ចីបំផុត

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា៨ ៈ—**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩ ៈ—**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០១

**ក្រុមលេខាធិការរាជរដ្ឋាភិបាល**

**ណារ៉ុ តាន់**

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ ន.ស/រ.ក.ត/០៧០១/២៦២
ចុះថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០០១ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ



# រូបសញ្ញារដ្ឋបាល

# សញ្ញាស័ក្តិមន្ត្រី ថ្នាក់ឧត្តមស័ក្តិឧត្តមមន្ត្រី (ពណ៌មាស)



ស័ក្តិករអាវ



ស័ក្តិប៉ានស្មា





ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិខ្សែក្រវាត់

ឧបសម្ព័ន្ធ ៤ នៃអនុក្រឹត្យលេខ .../អនក្រ/បក
ចុះថ្ងៃទី២៧ ខែ... ឆ្នាំ២០០១ ស្ដីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រី... និងក្របខ័ណ្ឌមន្ត្រីក្រមការ

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិអនុមន្ត្រី (ពណ៌មាស)

ស័ក្តិករអាវ




ស័ក្តិផ្ទាំងស្មា







ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៩២
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

# ស័ក្តិខ្ទាស់លើអាវសំរាប់មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល (ពណ៌មាស)



សំរាប់ឋានន្តរស័ក្តិឧត្តមមន្ត្រី



សំរាប់ឋានន្តរស័ក្តិវរៈមន្ត្រី



សំរាប់ឋានន្តរស័ក្តិអនុមន្ត្រី

...ឧបសម្ព័ន្ធ ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៥៥
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិនាយឧត្តមមន្ត្រី (ពណ៌ខ្មៅ)



សក្តិករ...



សក្តិបានស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤៤
ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

## សញ្ញាស័ក្តិមន្ត្រី ថ្នាក់ឧត្តមស័ក្តិក្រមការដើមខ្មែរ (ពណ៌ថ្នាក់)



ស័ក្តិករអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

## សញ្ញាសក្តិមន្ត្រី ថ្នាក់ឧត្តមសក្តិ ក្រុមភាគ (ពណ៌ប្រាក់)



ស័ក្តិករអាវ



ស័ក្តិប៉ានស្មា



## មេគំរូឯកសណ្ឋានផ្លូវការ សំរាប់បុរស និងស្ត្រី





## រូបគំនូរឯកសណ្ឋានប្រពៃណីជាតិ សំរាប់បុរស និងស្ត្រី



# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៤៤

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ខៀវ សារ៉ម៉េត ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០០១

លេខ: ១៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារ៉ា ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៨៥

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក **ហ្សង់ព្យែរ ម៉ាតស្យាល** ( Jean-Pierre MARTIAL ) សញ្ជាតិដើមបារាំង កើតនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៤៨ នៅស្រុក លីយ៉ុង នៃសាធារណរដ្ឋបារាំង ។

**មាត្រា២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ១៥៧ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី គាត់

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៤៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបំពាក់មេដាយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ជូនឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មការ ដើម្បីទប់ស្កាត់ទឹកជំនន់ ដែលមានស្នាដៃ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ ក្នុងការងារបំពេញបេសកកម្មដឹកនាំ និងការពារបាននូវទំនប់កប់ស្រូវ ជាទំនប់យុទ្ធសាស្ត្រសំរាប់ទប់ស្កាត់ទឹកជំនន់ នៃរាជធានីភ្នំពេញ ព្រមទាំងកាត់បន្ថយបាននូវការខូចខាតទ្រព្យសម្បត្តិ ផ្ទះសំបែង អាយុជីវិតរបស់ប្រជារាស្ត្រ នៅតាមតំបន់ដែលទទួលរងគ្រោះដោយទឹកជំនន់ទន្លេមេគង្គ ក្នុងឆ្នាំ ២០០០ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ១៥៣ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

ជ. អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងនិងផ្ទេរភារកិច្ចឯកឧត្តម ខែក ឡឺរ៉េ បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា

នរោត្តម សីហនុ

លេខ: ១៥៤ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០១ / ២៤៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

មាត្រា ១ : តែងតាំងឯកឧត្តម អ៊ឹង ហួត ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១

លេខ: ១៥៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឥណាឌី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០១ / ២៤៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

មាត្រា ១ : តែងតាំងលោកជំទាវ តេត ថុល ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៥៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១

[illegible]

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៥០

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម ញាណ ឡេង ជាអនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំនួសឯកឧត្តម អ៊ុត ឈន ដែលផ្លាស់ទៅទទួលភារកិច្ចថ្មី ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០១*

ឆ្នាំទី ៩ លេខ ២៨ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ១៩៦២

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៥១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ច័ន្ទ ខេអ៊ីម រដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ៦៧១ ម.ក

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

គាន់

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៥២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៨ ៣០ ៣៤ ៥១ ៩០ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៥ ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សំណើរបស់សម្តេចក្រុមព្រះ ព្រះប្រធានគណបក្ស ហ៊ុន ស៊ិន ប៊ិច ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ស៊ុន ពិនសេន (ហៅ ស៊ុន សេន) ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួសឯកឧត្តម ស៊ុន ម៉ូ ដែលបានលាឈប់ទៅបំពេញភារកិច្ចថ្មី ។

មាត្រា ២ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨/៧ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារ៉ុ តាន់

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០១

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

*************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## **សម្រេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៦០០ លានរៀល ( ប្រាំមួយរយលានរៀលគត់ ) ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយទូទាត់អគ្គីសនី សោហ៊ុយបេសកកម្ម ក្រៅប្រទេស និង សោហ៊ុយទទួលភ្ញៀវបរទេស ដែលខ្វះនៅចុងឆ្នាំ ២០០១ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០៧/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៥.០០០ លានរៀល ( ប្រាំពាន់លានរៀល ) ពីជំពូក ៤០ (ចំណាយផ្សេងៗ )ចំនួន ២.០០០ លានរៀល និង ជំពូក ១២ ( ឧបត្ថម្ភថវិកាឃុំ សង្កាត់ ) ចំនួន ៣.០០០ លានរៀល នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយ ដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់ ) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកា ចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់រៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០០១

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០៧/រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ / នស / ៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំ រេ ច

### ជំពូកទី ១

### អំពីការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា « ក.អ.ក » ដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១- សម្តេច ហ៊ុន សែន | នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម គាត ឈន់ | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣- ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- ឯកឧត្តម គង់ វិបុល | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ឬតំណាង | | សមាជិក |

| | |
|---|---|
| ៧- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតំណាង | សមាជិក |
| ៩- សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងពត៌មាន ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង | សមាជិក |
| ១៨- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឬតំណាង | សមាជិក |
| ២០- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ២១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ២២- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ២៣- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ២៤- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| ២៥- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ២៦- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |
| ២៧- រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច ឬតំណាង | សមាជិក |
| ២៨- រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឬតំណាង | សមាជិក |
| ២៩- អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬតំណាង | សមាជិក |
| ៣០- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង | សមាជិក |
| ៣១- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬតំណាង | សមាជិក |
| ៣២- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ឬតំណាង | សមាជិក |
| ៣៣- អគ្គនាយកនគរបាលជាតិ ឬ តំណាង | សមាជិក |
| ៣៤- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឬតំណាង | សមាជិក |
| ៣៥- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣៦- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ | សមាជិក |

៣៧- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

៣៨- អភិបាលខេត្ត- ក្រុង ឬ តំណាង សមាជិក

៣៩- ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឬតំណាង សមាជិក

**មាត្រា ២** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ហៅកាត់ «គ.ជ.នា» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ « គ.វ.ក» ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៣- អគ្គលេខាធិការដ្ឋាននៃ «ក.អ.ក » ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ « ក.អ.ក » ។ អគ្គលេខាធិការដ្ឋាននេះរួមមាន «ផ្នែកគាំទ្រ » ចំនួន ៤ ÷

- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល
- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក
- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ ។

**មាត្រា ៣** : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងអគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានអគ្គលេខាធិការរងមួយរូបៗរៀងៗខ្លួនសំរាប់ជាជំនួយការក្នុងការងារ ។ អគ្គលេខាធិការរងនីមួយៗបំពេញកិច្ចការតាមភារកិច្ចដែលអគ្គលេខាធិការប្រគល់អោយក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ។ អគ្គលេខាធិការមួយរូបៗ ត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន ។

**មាត្រា ៤** : គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ អូសទាញ និងសំរបសំរួលជំនួយ

២- ផ្នែកឯកសារ និងគ្រប់គ្រងពត៌មាន

៣- ផ្នែកគ្រប់គ្រងជំនួយទ្វេភាគី ÷

- ជប៉ុន និងអាស៊ី
- បារាំង និងអឺរ៉ុប
- អូស្ត្រាលី និងអូសេអានី
- សហរដ្ឋអាមេរិក

៤- ផ្នែកគ្រប់គ្រងជំនួយពហុភាគី ÷

- ធនាគារអភិវឌ្ឍន៍អាស៊ី

- ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
- សហគមន៍អឺរ៉ុប

៥- ផ្នែកគ្រប់គ្រងជំនួយរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិនិងបណ្តាអង្គការរបស់សហប្រជាជាតិ

៦- ផ្នែកសំរបសំរួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៧- ផ្នែកវិភាគគំរោង

៨- ផ្នែករដ្ឋបាល ។

**មាត្រា ៥** : គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែកការគ្រប់គ្រងពត៌មាន និងឯកសារ

២- ផ្នែកទំនាក់ទំនងសាធារណៈ និងការជំរុញគំរោងវិនិយោគឯកជន

៣- ផ្នែកវិភាគគំរោង និងការលើកទឹកចិត្ត

៤- ផ្នែកវាយតំលៃខាងបរិស្ថាន

៥- ផ្នែកសំរបសំរួលកិច្ចការអន្តរក្រសួង

៦- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៧- ផ្នែកនីតិវិធី និងច្បាប់វិនិយោគ

៨- ផ្នែករដ្ឋបាល ។

**មាត្រា ៦** : ផ្នែកនិងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូបជាជំនួយការ ។

**មាត្រា ៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ ÷

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ។

## ជំពូកទី ២

## អំពីសមត្ថកិច្ច និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ៨** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានសមត្ថកិច្ចដូចតទៅ ÷

១- ជាសេនាធិការ និងជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

២- ដឹកនាំការងាររៀបចំទស្សនទាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់ប្រទេសកម្ពុជា ដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ។

៣- ទាក់ទងជាមួយប្រទេស អង្គការអន្តរជាតិពហុភាគី/ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើអោយគេយល់ដឹងច្បាស់អំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃកម្មវិធីជាតិសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស ដើម្បីសំរបសំរួលការទទួល និងការប្រើប្រាស់ជំនួយអន្តរជាតិអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ។

៤- សំរបសំរួលការងាររវាងបណ្តាក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធ និងសំរបសំរួលការងាររវាងបណ្តាក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយ ព្រមទាំងជាមួយអ្នកវិនិយោគ ។

៥- តំរង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជន ក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

៦- លើកកំពស់ទំនាក់ទំនងការងារ និងសំរួលកិច្ចការដល់អ្នកផ្តល់ជំនួយ និងដល់អ្នកវិនិយោគ ។

៧- ពិនិត្យ និងសំរេចរាល់កិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ» នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៩** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សំរេចពីគណៈរដ្ឋមន្ត្រី លើគំរោងវិនិយោគទាំងឡាយ ដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ÷

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គំរោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គំរោង «សង់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស.អ.ផ» ឬ គំរោង «សង់-កាន់កាប់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស.ក.អ.ផ» ឬ គំរោង «សង់-កាន់កាប់-អាជីវកម្ម» ហៅកាត់ «ស.ក.អ» ឬ គំរោង «សង់-ជួល-ផ្ទេរ» ហៅកាត់ «ស.ជ.ផ» ។

**មាត្រា ១០** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន ។

**មាត្រា ១១** : ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ÷

១- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំទស្សនទានជាយុទ្ធសាស្ត្រសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស និងដើម្បីលើកឡើងនូវលំដាប់អាទិភាព នៃតំរូវការរបស់ប្រទេសជាតិ ក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងសំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង

ដើម្បីបង្កើតឡើងនូវកម្មវិធីការងាររំកិលតាមឆ្នាំ ។ កម្មវិធីនេះ ត្រូវមានលក្ខណៈជាប្រព័ន្ធរលូន ប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ។

២- រួមជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសំរាប់អភិវឌ្ឍន៍កម្ពុជា ។

៣- គ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសំរបសំរួល និងការតំរង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេសនិងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

៤- ធ្វើជាចំណុចប្រមូលផ្តុំ និងជា «ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងរាជរដ្ឋាភិបាលជាមួយនឹងប្រទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ និងជា«ច្រកចេញចូលតែមួយ» ក្នុងការទាក់ទងរវាងក្រសួង និងស្ថាប័ននានា នៃរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលការទទួលជំនួយ និង/ឬ ការបែងចែកជំនួយ ។

៥- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគីពហុភាគី និង/ឬ អង្គការអន្តរជាតិនានា ដើម្បីទទួលជំនួយនិង/ឬ បែងចែកជំនួយ ។

៦- សហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធដឹកនាំការងារ ក្នុងការរៀបចំឯកសារចាំបាច់នានាសំរាប់កិច្ចប្រជុំអន្តរជាតិ សំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ដូចជា «ក្រុមពិគ្រោះយោបល់សំរាប់កម្ពុជា » ជាដើម ។

៧- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគសាធារណៈ សំរាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើង នូវវិធានការចាំបាច់សំរាប់កែលំអ និងតំរង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍ ។

**មាត្រា ១២** : ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- «គ.អ.ក» ជាអ្នកសំរបសំរួលក្នុងការលើកទស្សនទាននៃជាយុទ្ធសាស្ត្រ និងគោលនយោបាយនៃកិច្ចការវិនិយោគសាធារណៈ ព្រមទាំងជាអ្នកសំរបសំរួល ក្នុងការកំណត់ លំដាប់អាទិភាពនៃកម្មវិធី និងគំរោងវិនិយោគសាធារណៈសំរាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្កួចការទូតផ្លូវការ ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នករៀបចំផែនការ ៥ ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នករៀបចំការប៉ាន់ស្មានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសំរាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ។

៥- ក្រសួងផែនការ ជាអ្នករៀបចំកម្មវិធី និងគំរោងការវិនិយោគសាធារណៈតាមផ្នែក ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ « ក.អ.ក » ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគំរោងការវិនិយោគសាធារណៈតាមផ្នែក ដែលមានការពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន ។

**មាត្រា ១៣** : ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួនខាងវិនិយោគសាធារណៈដោយសំរបសំរួលការងារជាមួយគ្នាតាមរយៈយន្តការ « ច្រកចេញចូលតែមួយ » ។

**មាត្រា ១៤** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តន៍កម្មវិធី និង/ឬ គំរោង ស្របតាមសមត្ថកិច្ចរៀងៗខ្លួន ដោយសំរបសំរួលក្នុងការងារជាមួយគ្នា តាមរយៈយន្តការ « ច្រកចេញចូលតែមួយ » ។

**មាត្រា ១៥** : ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- បំពេញតួនាទីជាយន្តការ « ច្រកចេញចូលតែមួយ » និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសំរេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ « ការប្រណាំងប្រជែងដណ្តើមយកឈ្នះ » លើទីផ្សារអន្តរជាតិសំរាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសំរាប់ប្រទេសកម្ពុជា និងសំរេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជា « សាជីវកម្មកម្ពុជា » ។ សហការជាមួយក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគំរោងនានាសំរាប់ការវិនិយោគឯកជន ។

៣- ផ្សព្វផ្សាយអំពីគំរោងនានាសំរាប់ការវិនិយោគឯកជនដែលរាជរដ្ឋាភិបាលបានលើកឡើងនិងផ្តល់គំរោងទាំងនោះទៅអោយអ្នកវិនិយោគតាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ញត្តិផ្ទៃក្នុង នៃ « ក.អ.ក » ។

៤- សំរបសំរួលការគ្រប់គ្រងគំរោង «សង់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស-អ-ផ» គំរោង «សង់-កាន់កាប់-អាជីវកម្ម-ផ្ទេរ» ហៅកាត់ «ស-ក-អ-ផ» គំរោង «សង់-កាន់កាប់-អាជីវកម្ម» ហៅកាត់ «ស-ក-អ» និងគំរោង «សង់-ជួល-ផ្ទេរ» ហៅកាត់ «ស-ជ-ផ» ។

៥- ផ្តួចផ្តើម និងសំរបសំរួលការគ្រប់គ្រងតំបន់អភិវឌ្ឍន៍ពិសេស ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ។

៦- លើកគំរោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗដែលទាក់ទិនទៅនឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតបរិក្ខខ័ណ្ឌ

ដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន ។

៧- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសំរាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់កែប្រែកែលំអ និងតំរង់ទិសការងារវិនិយោគឯកជន ។

**មាត្រា ១៦** : ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលត្រូវកំណត់ដូចតទៅ ៖

១- «ក.អ.ក» បំពេញតួនាទីជា «ច្រកចេញចូលតែមួយ» របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជននានា ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ «ច្រកចេញចូលតែមួយ» ដូចមានកំណត់នៅក្នុងមាត្រា ២៩ ។

**មាត្រា ១៧** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសំរបសំរួលការងារជាមួយគ្នា តាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

**មាត្រា ១៨** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬ ស្ថាប័ន ដែលមានការពាក់ព័ន្ធ ជាអ្នកតាមដានការអនុវត្តន៍គំរោងវិនិយោគឯកជន ដែល«ក.អ.ក» បានផ្តល់ការអនុញ្ញាតហើយ ដោយសំរបសំរួលការងារជាមួយគ្នាតាមរយៈយន្តការ «ច្រកចេញចូលតែមួយ» ។

## ជំពូកទី ៣

## ការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា ១៩** : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ :

១- ទទួលខុសត្រូវរួមលើការងាររបស់ « ក.អ.ក » ។

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក » និង អង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ។

៣- ដឹកនាំពិភាក្សានិងថែរក្សាសណ្តាប់ធ្នាប់ នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និងអង្គប្រជុំពេញអង្គ « ក.អ.ក » ។

៤- ចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងអង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៥- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងប្រជុំវិសាមញ្ញ ពេញអង្គរបស់ «ក.អ.ក» ។

៦- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ «ក.អ.ក» ។

**មាត្រា ២០** : អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ :

ក- ឯកឧត្តម **គាត ឈន់** អនុប្រធានទី ១÷

១- ទទួលខុសត្រូវរួមលើការងាររបស់ «ក.អ.ក» ក្នុងករណីដែល ប្រធាន «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជារួម ។

៣- មមូលបន្ទុកការងាររបស់គណៈកម្មាធិការរបស់នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតសំខាន់ទៅលើការសំរបសំរួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសំរបសំរួលជំនួយបរទេស ។

៤- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ «ក.អ.ក» ។

៥- ធ្វើជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និង អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» និងចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំនោះ ក្នុងករណីដែលប្រធាន «ក.អ.ក» អវត្តមាន ។

៦- ទទួលបន្ទុកក្នុងការសំរបសំរួលការងារអន្តរក្រសួងរវាង «ក.អ.ក» ជាមួយនឹងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល ។

៧- ទទួលបន្ទុកក្នុងការទាក់ទងជាមួយប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយនានា ។

៨- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើង ដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការងារវិនិយោគនានា មុននឹងដាក់ស្នើសុំសេចក្តីសំរេចពីអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ។

៩- បំពេញការងារដទៃទៀតដែលប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

ខ- ឯកឧត្តម **ចម ប្រសិទ្ធ** អនុប្រធាន÷

១- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលប្រធាន និងអនុប្រធានទី១ នៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន និងកិច្ចការដឹកនាំអនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និង

យុទ្ធសាស្ត្រនេះ ដោយរាប់បញ្ចូលទាំងការរៀបចំតំបន់ពាណិជ្ជកម្មសេរី តំបន់កែច្នៃសំរាប់ការនាំចេញ និងតំបន់ឧស្សាហកម្មពិសេសផ្សេងៗទៀត ។

៣- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន ។

៤- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក» ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ។

៥- បំពេញការងារដទៃទៀតដែលប្រធាន « ក.អ.ក » ប្រគល់សិទ្ធិ ។

គ- ឯកឧត្តម **គង់ វិបុល** អនុប្រធាន ÷

១- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក » ក្នុងករណីដែលប្រធាន និងអនុប្រធានទាំងពីររូបនៃ «ក.អ.ក» អវត្តមាន ។

២- ទទួលបន្ទុកការងារប្រចាំរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដែលរៀបចំឡើងដោយ «ក.អ.ក » ដើម្បីពិនិត្យឯកភាពក្នុងយន្តការ «ច្រកចេញចូលតែមួយ» លើការងារវិនិយោគឯកជន ក្នុងករណីឯកឧត្តម ចម ប្រសិទ្ធ អវត្តមាន ឬជាប់រវល់ដោយប្រការណាមួយ ។

៤- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសំរបសំរួលជាមួយអនុប្រធានពីររូបទៀត ។

៥- ទទួលខុសត្រូវលើការងាររបស់ «ក.អ.ក» ក្នុងករណីដែលប្រធាន និងអនុប្រធានពីររូបទៀតនៃ «ក.អ.ក» អវត្តមាន ។

៦- បំពេញការងារដទៃទៀតដែលប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២១** : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- ទទួលបន្ទុកក្នុងការសំរបសំរួល និងតាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងគណៈកម្មាធិការវិនិយោគកម្ពុជា ព្រមទាំងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ«ក.អ.ក»។

២- ធ្វើជាសេនាធិការបច្ចេកទេសអោយ «ក.អ.ក» ក្នុងការដឹកនាំអនុវត្ត និងតាមដានការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ ពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន ។

៣- រៀបចំកម្មវិធីការងាររបស់ «ក.អ.ក» និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងសំរាប់អង្គប្រជុំពេញអង្គរបស់ «ក.អ.ក» ។

៤- រៀបចំកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» និងនៃអង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ដើម្បីដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខា ។

៥- រៀបចំសេចក្តីប្រកាសពត៌មានរបស់ « ក.អ.ក » ។

៦- ជួយសំរបសំរួលការរៀបចំរបាយការណ៍ប្រចាំខែមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និង អភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និងអនុម័ត មុននឹងផ្ញើជូន រាជរដ្ឋាភិបាល ។

៧- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសំរេចលើកិច្ចការ នីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា ។

៨- បំពេញការងារដទៃទៀត ដែលប្រធាន «ក.អ.ក» ឬ អនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

៩- ទទួលបន្ទុកជាអគ្គលេខាធិការនៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ។

**មាត្រា ២២ :** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ « គ.ជ.នា » ។

២- រៀបចំរបៀបវារៈ និងឯកសារសំរាប់អង្គប្រជុំនយន្តការ «ច្រកចេញចូលតែមួយ »ដែលមានការ ទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទង ទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និងសំរាប់អង្គប្រជុំពេញអង្គរបស់ « ក.អ.ក »។

៤- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការ ជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើក យោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ដើម្បីពិនិត្យ និងចាត់វិធានការណ៍កែតំរូវក្នុង ករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក» ក្នុងការរៀបចំរបាយការណ៍ប្រចាំខែមាស និងប្រចាំឆ្នាំលើផ្នែក ការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូន «ក.អ.ក» ពិនិត្យ និង អនុម័ត មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេចលើកិច្ចការ នីតិសម្បទា និងអភិវឌ្ឍន៍ ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ស្របតាមការ ប្រគល់ភារកិច្ចពីប្រធាន «ក.អ.ក» ឬ អនុប្រធាន «ក.អ.ក» ប្រគល់សិទ្ធិ ។

**មាត្រា ២៣ :** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ « គ.វ.ក »

២- រៀបចំរបៀបវារៈ និងឯកសារសំរាប់អង្គប្រជុំយន្តការ «ច្រកចេញចូលតែមួយ» ដែលមានការ ទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន ។

៣- ជួយដល់អគ្គលេខាធិការ « ក.អ.ក » ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » និងសំរាប់អង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ។

៤- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ដើម្បីពិនិត្យនិងចាត់វិធានការកែតំរូវក្នុងករណីចាំបាច់

៥- ជួយដល់អគ្គលេខាធិការ «ក.អ.ក » ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន « ក.អ.ក » ពិនិត្យ និងអនុម័តមុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេចលើកិច្ចការវិនិយោគឯកជន ។

៧- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ស្របតាមការប្រគល់ភារកិច្ចពីប្រធាន ឬ អនុប្រធាន « ក.អ.ក » ប្រគល់សិទ្ធិ ។

**មាត្រា ២៤** : សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគំរោងវិនិយោគនានា ទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន ។

២- ចូលរួមក្នុងការត្រួតពិនិត្យ ការអនុវត្តន៍គោលនយោបាយកម្មវិធី និងគំរោងវិនិយោគនានា ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័ត ទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន ។

៣- ពិនិត្យ និងអនុម័ត របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**មាត្រា ២៥** : គណៈកម្មាធិការប្រតិបត្តិនៃ « ក.អ.ក » ត្រូវអញ្ជើញចូលរួមប្រជុំក្នុងពីរអាទិត្យម្តង ។

**មាត្រា ២៦** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកោះប្រជុំពេញអង្គក្នុងមួយខែម្តង ។

**មាត្រា ២៧** : ក្នុងករណីចាំបាច់ ប្រធាន « ក.អ.ក » អាចនឹងកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក» ឬ ប្រជុំវិសាមញ្ញពេញអង្គរបស់ «ក.អ.ក» ។

**មាត្រា ២៨**: ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ «ក.អ.ក » និងអង្គប្រជុំពេញអង្គរបស់ « ក.អ.ក » ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក » ។

**មាត្រា ២៩:** ការអនុវត្តន៍ការងារនៃយន្តការ «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ ដូចខាងក្រោម ÷

**ទី១-** សំរាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ÷

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាន ឬ អនុប្រធាននាយកដ្ឋានមួយរូប អោយមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។ មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្ថិតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ « ច្រកចេញចូលតែមួយ » នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ « អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.ជ.នា » ចំពោះតែកិច្ចការវិនិយោគសាធារណៈណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង ស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ «គ.ជ.នា» មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរមួតពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃស្ថាប័ន «ច្រកចេញចូលតែមួយ» ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុតាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំពេលកម្មវិធី ឬ គំរោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ « ច្រកចេញចូលតែមួយ » ដើម្បីពិនិត្យ និងសំរេច ។

ង- អគ្គលេខាធិការ « គ.ជ.នា » ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ » បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ « ក.អ.ក » ពិនិត្យ និងសំរេច ។

**ទី២-** សំរាប់គណៈកម្មាធិការវិនិយោគកម្ពុជា ÷

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងប៉ុស្តិ៍ និងទូរគមនាគមន៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់

ប្រធាន ឬ អនុប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការវិនិយោគកម្ពុជា ។ មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមខេត្តនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្ថិតរមួតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃទៀត នៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងសំរាប់ចូលរួមក្នុងយន្តការ « ច្រកចេញចូលតែមួយ » នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ « អែដហុក » តាមការអញ្ជើញរបស់អគ្គលេខាធិការ « គ.វ.ក » ចំពោះតែគំរោងការវិនិយោគឯកជនណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ «គ.វ.ក» មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសំរេចក្នុងអង្គប្រជុំនៃយន្តការ «ច្រកចេញចូលតែមួយ» ដល់តំណាងក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាពេញលេញសព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ «គ.វ.ក» ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគំរោងនោះ ទៅក្នុងអង្គប្រជុំ នៃយន្តការ «ច្រកចេញចូលតែមួយ» ដើម្បីពិនិត្យ និងសំរេច ។

ង- អគ្គលេខាធិការ «គ.វ.ក» ត្រូវរៀបចំសំណុំឯកសារ និងពត៌មានផ្សេងៗ ដែលជាលទ្ធផល នៃកិច្ចប្រជុំរបស់យន្តការ « ច្រកចេញចូលតែមួយ» បញ្ជូនទៅអគ្គលេខាធិការ « ក.អ.ក » ដើម្បីរៀបចំដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ « ក.អ.ក» ពិនិត្យ និងសំរេច ។

ទី៣- ក្រោយពីបានទទួលគ្រប់គ្រាន់នូវឯកសារ និងពត៌មានផ្សេងៗ ពីអគ្គលេខាធិការ «គ.ជ.ន» និងអគ្គលេខាធិការ «គ.វ.ក » មក អគ្គលេខាធិការ «ក.អ.ក » ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ «ក.អ.ក» ដើម្បីពិនិត្យ និងសំរេច ។

**មាត្រា ៣០** : សេចក្តីលំអិតអំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃស្ថាប័ន «ច្រកចេញចូលតែមួយ» របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ «ក.អ.ក» ។

**មាត្រា ៣១** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការនិងមានខ្ទង់ចំណូលនិងចំណាយថវិកាដោយឡែក ។ ការគ្រប់គ្រងចំណូលនិងចំណាយថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

**មាត្រា ៣២** : អនុក្រឹត្យលេខ ៥១ / អនក្រ.បក / ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ និងអនុក្រឹត្យលេខ ៤៨ / អនក្រ.បក / ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៣
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# បទដ្ឋាន និង នីតិវិធីគ្រប់គ្រងចំណូល-ចំណាយ សំរាប់ដំណើរការការ បោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់

*****

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម១២៩៧-០៦-ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស / រកម ០៣០១/០៤ ចុះ ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានឃើញព្រះរាជក្រមលេខ ០១ ន ស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ១៩៩៤

-បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៣៩៨/០៤ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតគណនីពិសេសរបស់រតនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សំរេច

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់នីតិវិធីសំរាប់ការគ្រប់គ្រង និង ប្រើប្រាស់ធនធានទាំងឡាយនៃគណនីពិសេស របស់ធនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

មូលនិធិទាយជ្ជទានដែលមានក្នុងគណនីពិសេសរបស់ធនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកត់ត្រាក្នុងជំពូក ៦១.០៤.១៤.០១ ។

**មាត្រា៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិសុំបុរេប្រទាននូវថវិកាដែលផ្តល់ដោយរាជរដ្ឋាភិបាល និង ថវិកាជាអំណោយនានារបស់សហគមន៍អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សប្បុរសជន និង ចំណូលស្របច្បាប់ផ្សេងៗទៀត ដែលមានតំកល់ទុកនៅក្នុងគណនីពិសេសរបស់ធនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីយកមកធ្វើការចំណាយផ្សេងៗជាមុន ក្នុងដំណើរការរៀបចំការបោះឆ្នោត និង ធ្វើការទូទាត់ជាក្រោយរួមទាំងការចំណាយសំរាប់ប្រាក់ឧបត្ថម្ភ និង ប្រាក់កំរៃដល់សមាជិក គ.ជ.ប និង មន្ត្រី បុគ្គលិកដែលត្រូវជ្រើសរើសសំរាប់ប្រតិបត្តិការបោះឆ្នោតនេះ ។

**មាត្រា៤.-**

ចំនួនទឹកប្រាក់ដែលស្នើសុំបុរេប្រទាន មិនត្រូវអោយលើសពីថវិកាដែលមាននៅក្នុងគណនីពិសេស ឡើយ ។

**មាត្រា៥.-**

សមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង អគ្គលេខាធិការ អគ្គលេខាធិការរង ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់ដូចខាងក្រោម ចាប់ពីថ្ងៃទទួលភារកិច្ច ពីរាជ រដ្ឋាភិបាលៈ

| | | | |
|---|---|---|---|
| - | ប្រធាន គ.ជ.ប ត្រូវបាន | ៦.០២៧.៩០០ | រៀល |
| - | អនុប្រធានគ.ជ.ប ត្រូវបាន | ៥.៤៩៦.៨០០ | រៀល |
| - | សមាជិក គ.ជ.ប ត្រូវបាន | ៥.៣១៨.៧០០ | រៀល |
| - | អគ្គលេខាធិការ ត្រូវបាន | ៤.០០០.០០០ | រៀល |
| - | អគ្គលេខាធិការរង ត្រូវបាន | ២.៨០០.០០០ | រៀល |

មន្ត្រី បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និង សមាជិក គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ លំដាប់ថ្នាក់ និង មន្ត្រីបុគ្គលិកដទៃទៀត ត្រូវបានទទួលប្រាក់កំរៃតាមសេចក្តីសំរេចរបស់ គ.ជ.ប ស្តីពីការកំណត់ប្រាក់កំរៃ សំរាប់មន្ត្រីបុគ្គលិកបំរើការនៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ចាប់ពីថ្ងៃដែល ត្រូវបានតែងតាំងជាផ្លូវការ ។

មាត្រា៦.-

ប្រាក់ឧបត្ថម្ភ និង ប្រាក់កំរៃសំរាប់សមាជិក មន្ត្រី បុគ្គលិកគ្រប់លំដាប់ថ្នាក់ត្រូវបានបើកផ្តល់នៅដំណាច់ខែនិមួយៗ។

មាត្រា៧.-

របបឧបត្ថម្ភជីវភាពចំណាយ សំរាប់ផ្តល់ជូនសមាជិក គ.ជ.ប សមាជិកគណៈកម្មការគ្រប់លំដាប់ថ្នាក់ និង មន្ត្រី បុគ្គលិកនានាបំរើការសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅពេលបំពេញបេសកកម្មក្នុងប្រទេស ត្រូវបាន កំណត់ដូចខាងក្រោម:

-សមាជិក គ.ជ.ប មន្ត្រី និង បុគ្គលិកបំរើការនៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ឆ្លងខេត្ត

១- ប្រភេទ ក : សមាជិក គ.ជ.ប

- ឧបត្ថម្ភរបបបេសកកម្មចំនួន : ២០.០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ហូបចុកចំនួន : ៤០.០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ស្នាក់នៅចំនួន : ១០០.០០០ ៛ ០០ ក្នុងមួយថ្ងៃ

២- ប្រភេទ ខ : អគ្គលេខាធិការ ,អគ្គលេខាធិការរង ,ប្រធាន អនុប្រធាននាយកដ្ឋាន និង ទីប្រឹក្សា គ.ជ.ប នាយខុទ្ទកាល័យ ,ប្រធានការិយាល័យពត៌មានសាធារណៈ

- ឧបត្ថម្ភរបបបេសកកម្មចំនួន : ១២.០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ហូបចុកចំនួន : ២៨.០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ស្នាក់នៅចំនួន : ៦០.០០០ ៛ ០០ ក្នុងមួយថ្ងៃ

៣- ប្រភេទ គ : មន្ត្រី បុគ្គលិកគ.ជ.ប

- ឧបត្ថម្ភរបបបេសកកម្មចំនួន : ៨ .០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ហូបចុកចំនួន : ១៥ .០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ស្នាក់នៅចំនួន : ៣៨ .០០០ ៛ ០០ ក្នុងមួយថ្ងៃ

- សមាជិក និង មន្ត្រី បុគ្គលិក គ.ខ/គ.ឃ ឡើងមក គ.ជ.ប (ឆ្លងខេត្ត)

- ឧបត្ថម្ភរបបបេសកកម្មចំនួន : ៨ .០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ហូបចុកចំនួន : ១៥ .០០០ ៛ ០០ ក្នុងមួយថ្ងៃ
- ឧបត្ថម្ភប្រាក់ស្នាក់នៅចំនួន : ៣៨ .០០០ ៛ ០០ ក្នុងមួយថ្ងៃ

- សមាជិក និង មន្ត្រី បុគ្គលិក ថ្នាក់ខេត្ត ក្រុងទៅឃុំ សង្កាត់ ឬ ថ្នាក់ឃុំ សង្កាត់ ឡើងមកខេត្ត ក្រុង ដោយឆ្លងស្រុក ខណ្ឌ (ចំងាយផ្លូវគិតតាមចំណាយផ្លូវកាត់ចាប់ពីដប់ប្រាំ

(១៥ គីឡូម៉ែត្រឡើងទៅ)

- ឧបត្ថម្ភបេសកកម្មចំនួន : ៨.០០០ ៛ ០០ ក្នុងមួយថ្ងៃ

- ឧបត្ថម្ភប្រាក់ហូបចុកចំនួន : ៨.០០០ ៛ ០០ ក្នុងមួយថ្ងៃ

- ចំពោះសមាជិក មន្ត្រី បុគ្គលិក ក្នុងគណៈកម្មការឃុំ សង្កាត់ដែលឡើងមក គ.ខ/គ.ប ហើយវិលត្រឡប់ទៅ គ.ឃ/ស.ប វិញមិនទាន់ក្នុងថ្ងៃដែលសាមីខ្លួនឡើងមកដោយហេតុមានបញ្ហា ឬ ករណីចាំបាច់ណាមួយត្រូវបានឧបត្ថម្ភការស្នាក់នៅ ៨.០០០៛០០/ថ្ងៃ។ ចំពោះករណីនេះ គ.ខ/គ.ប ត្រូវធ្វើការបញ្ជាក់ច្បាស់លាស់អំពីបញ្ហា ឬ ករណីចាំបាច់នោះ ។

**មាត្រា៨.-**

រយៈពេលបំពេញបេសកកម្មយូរបំផុតត្រឹម ១០ថ្ងៃ លើកលែងតែមានករណីពិសេសដែលទាក់ទងនឹងការងារបច្ចេកទេស តែមិនត្រូវអោយលើសពី ១៥ថ្ងៃឡើយ។ បើលើសពីនេះចាំបាច់ត្រូវមានបញ្ជាបេសកកម្មបន្ត តែក៏មិនលើសពី ២០ថ្ងៃ ក្នុងខែ ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវលើកតំរោងជាក់ស្តែងអំពីលក្ខណៈលំបាកដោយកន្សែកប្ប ពិសេសនៃការធ្វើដំណើរក្នុងខេត្តក្រុងរៀងៗខ្លួនមក គ.ជ.ប ដើម្បីសំរេចកំណត់ប្រាក់ឧបត្ថម្ភបេសកកម្ម ។

**មាត្រា៩.-**

ហិរញ្ញប្បទាន ក្រៅប្រទេសមួយចំនួន សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាចអនុវត្តដោយប្រតិបត្តិការក្រៅធនាគារជាតិ ។

**មាត្រា១០.-**

គ.ជ.ប ត្រូវរៀបចំកម្មវិធីចំណូល និង កម្មវិធីចំណាយ តាមកំរិតធនធានដែលមាន និង ត្រូវបញ្ជូនទៅរដ្ឋសភាដោយផ្ញើអត្ថបទចំលងទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គ.ជ.ប ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកម្មវិធី ចំណូល និង កម្មវិធីចំណាយក្នុងរយៈពេលយ៉ាងយូរបីខែបន្ទាប់ពីពេលប្រកាសលទ្ធផលជាស្ថាពរ ។ របាយការណ៍ត្រូវបញ្ជូនទៅរដ្ឋសភាដោយផ្ញើ អត្ថបទ ចំលងទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា១១.-**

ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ជាស្ថាពរ រួមទាំងក្រោយការបោះឆ្នោតសាជាថ្មី និង ផ្ទៀងផ្ទាត់វិញប្រសិនបើមាន ប្រាក់ឧបត្ថម្ភប្រចាំខែសំរាប់សមាជិក គ.ជ.ប និង អគ្គលេខាធិការ អគ្គលេខាធិការរង ដែលបន្តនិរន្តរភាពការងារ ត្រូវបានកំណត់ដូចខាង ក្រោម:

- ប្រធាន គ.ជ.ប ត្រូវបាន ៣.៨២៧.៨៦០ រៀល
- អនុប្រធានគ.ជ.ប ត្រូវបាន ៣.២៩៦.៧៥០ រៀល
- សមាជិក គ.ជ.ប ត្រូវបាន ៣.១១៨.៦៣០ រៀល
- អគ្គលេខាធិការ ត្រូវបាន ១.៤៦៨.៧៧០ រៀល
- អគ្គលេខាធិការរង ត្រូវបាន ៧៦០.០០០ រៀល

មន្ត្រី បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និង មន្ត្រី បុគ្គលិកតាមខេត្ត ក្រុងដែលត្រូវបានចាត់តាំងអោយបន្តនិរន្តរភាព

**ការងារ ត្រូវបានទទួលប្រាក់កំរៃតាមសេចក្តីសំរេចរបស់ គ.ជ.ប ស្តីពីការកំណត់ ប្រាក់កំរៃសំរាប់មន្ត្រី បុគ្គលិក បំរើការនៅពេលបន្តនិរន្តរភាព ។**

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ឆេង ផុន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ និង កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេល បំពេញការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សំរេច

**មាត្រា ១.-**

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធនិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ២.-**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត មន្ត្រីបំរើឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីបំរើឱ្យ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៣.-**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។ ក្នុងការឈប់ពិសេសនេះ សាមីខ្លួនត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

**មាត្រា ៤.-**

មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាសមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងការឈប់ពិសេសនេះ មន្ត្រីរាជការត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

**មាត្រា ៥.-**

គ្រប់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរាជការដែល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសរើស និងតែងតាំងឱ្យចូលរួមក្នុងការងារបោះឆ្នោត បានឈប់ពីការងារតាមសំណូមពរ និងបានចូលបំរើការងារនៅអង្គភាពដើមវិញក្រោយពេលចប់ភារកិច្ច ។

មន្ត្រីរាជការដែលទទួលបានការជ្រើសរើស និងតែងតាំងដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំចូលបំរើការងារវិញតាមឋានានុក្រមនៃក្រសួង ស្ថាប័នសាមី ។

លិខិតអនុញ្ញាតអោយឈប់ពិសេស និងលិខិតអនុញ្ញាតឱ្យចូលបំរើការងារវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦.-**

មន្ត្រីរាជការ ដែលត្រូវបានចាត់តាំងអោយបន្តនិរន្តរភាពការងារបោះឆ្នោត នៅគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត ត្រូវសុំបន្តការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី មានសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតែងតាំង អោយបន្តការងាររហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៧.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការ ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**ឆេង ផុន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខៈ ៣១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សំរេច

**មាត្រា ១** : តែងតាំងមន្ត្រីថ្នាក់នាយកដ្ឋានចំនួន ០៤រូប របស់ក្រសួងយុត្តិធម៌ ដូចមានរាយនាមខាងក្រោម :

១- លោក **អ៊ិត រ៉ាឌី** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ

២- លោក **ឃួត ធុនី** ជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

៣- លោក **គុង ពាង** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

៤- លោក **សេង ស៊ីវត្ថា** ជាប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងអនុគ្រោះទោស

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

SMet3b

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

លេខ: ៣១៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណូមពរការងារចាំបាច់

## ស ម្រេ ច

**មាត្រា ១** : តែងតាំងមន្ត្រីថ្នាក់នាយកដ្ឋានចំនួន ០២រូប របស់ក្រសួងយុត្តិធម៌ ដូចមានរាយនាមខាងក្រោម :

១- លោក **យូរ ឧត្តរា** ជាប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ

២- លោក **ស៊ីខ បញ្ញាធុន្ឋ** ជាប្រធាននាយកដ្ឋានកិច្ចការអយ្យការ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣១៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **សោភ ទ៉េត** បច្ចុប្បន្នប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១*

<u>ចម្លងជូន</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៣១៧ អនក្រ.តត**

# អនុក្រឹត្យ
## ស្តីពីការតែងតាំងទីប្រឹក្សាស្ថានទូត

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក ហេម ហេង បច្ចុប្បន្នអនុប្រធាននាយកដ្ឋាន អាស៊ី ប៉ាស៊ីហ្វិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១*

<u>ចម្លងជូន</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣១៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ :** ត្រូវបានផ្លាស់លោក **ឃែម ហេង** បច្ចុប្បន្នអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌា អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣១៥ អនក្រ/បត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ « **ធិបឌិន្ទ** » ជូនលោកជំទាវ **ផ្លេក ភិរុណ** អតីតប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា ដែលមានស្នាដៃ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ និងជួយសង្គ្រោះប្រជាពលរដ្ឋ រួមចំណែកជាមួយរាជរដ្ឋាភិបាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១*

**ហ៊ុន សែន**

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣២០ អនក្រ/ចត

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយសុវត្ថារា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ « **ធិបឌិន្ទ** » ជូនឯកឧត្តមអ្នកឧកញ៉ាវិសេសវិជ្ជាវេជ្ជ. **មី សាម៉ឺឌី** អគ្គលេខាធិការសមាគមជាតិកាកបាទក្រហមកម្ពុជា ដែលមានស្នាដៃ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ និងជួយសង្គ្រោះប្រជាពលរដ្ឋ រួមចំណែកជាមួយរាជរដ្ឋាភិបាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន :</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុធម្មា

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុធម្មា** ថ្នាក់ **សេនា** ជូនតំណាងអង្គការ JICA ០១ រូប និង តំណាងក្រុមហ៊ុន Sanyo Consultants Inc ចំនួន ០១ រូប ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងការផ្តល់ជំនួយសំរាប់អភិវឌ្ឍន៍ លើវិស័យធនធានទឹក និង ឧតុនិយម ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក Masao Miyazaki ជំនាញការ JICA អមក្រសួងធនធានទឹក និង ឧតុនិយម

២-លោក Hitoshi Toku តំណាងក្រុមហ៊ុន Sanyo Consultants Inc ប្រចាំគំរោងព្រែកនាំជីលូប្រាប់ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជនចំនួន ១០ រូប ដែលបានបរិច្ចាគនូវបច្ច័យ និង ថវិកា ដើម្បីកសាងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដូចមានរាយព្រះនាមនិង នាមខាងក្រោមនេះ ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះភិក្ខុសិរីវិសុទ្ធវង្ស | **អ៊ុំ** | **សារិទ្ធ** | បច្ច័យចំនួន ១០.០០០ ដុល្លារអាមេរិក |
| ២-ឯកឧត្តម | **ស្បោង** | **សារ៉ាត់** | ថវិកាចំនួន ១៩.២១៥ ដុល្លារអាមេរិក |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះភិក្ខុសុមេធវង្ស | **ស៊ុយ** | **ថេរ** | បច្ច័យចំនួន ៨.០០០ ដុល្លារអាមេរិក |
| ២-ព្រះតេជគុណ | **ម៉ែន** | **ញៀម** | បច្ច័យចំនួន ៥.០០០ ដុល្លារអាមេរិក |
| ៣-លោកស្រី | **ឌូ** | **ឈឹមហុង** | ថវិកាចំនួន ៨.០០០ ដុល្លារអាមេរិក |
| ៤-លោក | **ឌូ** | **សុទ្ធញ្ញា** | ថវិកាចំនួន ៨.០០០ ដុល្លារអាមេរិក |
| ៥-លោកយាយឧបាសិកា | **អ៊ុច** | **សោ** | ថវិកាចំនួន ៧.៥០០ ដុល្លារអាមេរិក |
| ៦-ឯកឧត្តម | **ម៉ុម** | **ស៊ីហុន** | ថវិកាចំនួន ៥.៣៥០ ដុល្លារអាមេរិក |

៧-លោក **ឈើម សុឃុន** ថវិកាចំនួន ៥.០០០ ដុល្លារអាមេរិក

៨-លោក **ឆាំង សៀងគៀង** ថវិកាចំនួន ៥.០០០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ប្រគេន និង ជូន ព្រះតេជគុណគ្រប់ព្រះអង្គ ជាមន្ត្រីសង្ឃ ថ្នាក់ខេត្ត ស្រុក និង មន្ត្រីធម្មការ និង សាសនាខេត្តតាកែវ ដែលបានខិតខំយកព្រះទ័យ និងយកចិត្តទុកដាក់ក្នុងការកសាងសមិទ្ធផលជាច្រើនដល់សង្គមជាតិ សំខាន់វិស័យព្រះពុទ្ធសាសនា អោយមានការរីកចំរើន ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ ÷

**ក-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១-ព្រះតេជគុណ **ជៀស អោម** ព្រះមេគណ ខេត្ត

២-លោក **ពុធ ខូច** ប្រធានមន្ទីរធម្មការ និងសាសនាខេត្ត

**ខ-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១-លោក **សិល សុខសារ៉ែន** អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត

២-លោក **កែវ ហ៊ុច** អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត

**គ-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១-ព្រះតេជគុណ **ជុន ឃុយ** ព្រះអនុគណ ស្រុកកោះអណ្តែត

២-ព្រះតេជគុណ **ជាន់ និន** ព្រះអនុគណ ស្រុក គិរីវង់

៣-ព្រះតេជគុណ **ខាត់ យស** ព្រះអនុគណ ស្រុក ទ្រាំង

៤-ព្រះតេជគុណ ឈឹម សុខឃ្លា ព្រះអនុគណ ស្រុក ដូនកែវ
៥-ព្រះតេជគុណ ខែម សុខ ព្រះអនុគណ ស្រុក ត្រាំកក់
៦-ព្រះតេជគុណ ឡុង នៅ ព្រះអនុគណ ស្រុក សំរោង
៧-ព្រះតេជគុណ យុត ឆៃល ព្រះអនុគណ ស្រុក ព្រៃកប្បាស
៨-ព្រះតេជគុណ ម៉ើន សួន ព្រះអនុគណ ស្រុក បាទី
៩-ព្រះតេជគុណ នង វីរៈ ព្រះអនុគណ ស្រុក អង្គរបុរី
១០-ព្រះតេជគុណ ឌី ចក់ ព្រះអនុគណ ស្រុក បុរីជលសា

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនលោក ទិត ឌួ ដែលបានចំណាយថវិកាផ្ទាល់ខ្លួនចំនួន ២១.៧០០ ដុល្លារអាមេរិក ដើម្បីកសាងសាលារៀន ០១ ខ្នង មាន ០៥ បន្ទប់ ស្ថិតនៅក្នុងភូមិក្រាំងស្គរ ឃុំក្រាំងតាយ៉ង ស្រុកពាមជរ ខេត្តព្រៃវែង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ ✓

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៣២៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/ ១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនក្នុង និង ក្រៅប្រទេសចំនួន ២៨ រូប ដែលបានធ្វើវិភាគទានស្ម័គ្រចិត្តជួយ ជួសជុល និង កសាងអាគារទីស្នាក់ការ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដូចមាន រាយនាមខាងក្រោមនេះ :-

**ក- មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- លោកឧកញ៉ា | **សុខ** | **គង់** | បានធ្វើវិភាគទាន : ៥០.០០០ USD |
| ២- លោកឧកញ៉ា | **ម៉ែន** | **សារុន** | បានធ្វើវិភាគទាន : ២៣.០០០ USD |
| ៣- លោកឧកញ៉ា | **សួ** | **សុវណ្ណ** | បានធ្វើវិភាគទាន : ២០.០០០ USD |
| ៤- លោកជំទាវ | **គួ** | **គីមឡុង** | បានធ្វើវិភាគទាន : ១៥.០០០ USD |
| ៥- លោកឧកញ៉ា | **ហង់** | **ឃឿង** | បានធ្វើវិភាគទាន : ១១.០០០ USD |
| ៦- លោក | **តែ** | **តាំងប៉ោ** | បានធ្វើវិភាគទាន : ១០.៦០០ USD |
| ៧- លោកឧកញ៉ា | **ស៊ិន** | **សុខណា** | បានធ្វើវិភាគទាន : ១០.០០០ USD |
| ៨- លោកឧកញ៉ា | **គង់** | **ទ្រីវ** | បានធ្វើវិភាគទាន : ១០.០០០ USD |
| ៩- លោកឧកញ៉ា | **គុក** | **អាន** | បានធ្វើវិភាគទាន : ១០.០០០ USD |
| ១០- លោកឧកញ៉ា | **លី** | **យ៉ុងផាត់** | បានធ្វើវិភាគទាន : ១០.០០០ USD |
| ១១- លោក | **សាម** | **ប៊ុនហេង** | បានធ្វើវិភាគទាន : ១០.០០០ USD |
| ១២- លោកជំទាវ | **សោម** | **សុផល** | បានធ្វើវិភាគទាន : ១០.០០០ USD |

១៣- លោកស្រី ចាន់ សុន្ធា បានធ្វើវិភាគទាន : ១០.០០០ USD
១៤- លោក លី គួយ បានធ្វើវិភាគទាន : ១០.០០០ USD
១៥- លោក ឡៅ ស៊ីអ៊ុយ បានធ្វើវិភាគទាន : ១០.០០០ USD
១៦- លោក ហ៊ី ហេង បានធ្វើវិភាគទាន : ១០.០០០ USD
១៧- លោក ម៉ែន សុជាតិ បានធ្វើវិភាគទាន : ១០.០០០ USD
១៨- លោក សុខ ចន្ធា បានធ្វើវិភាគទាន : ១០.០០០ USD

ខ- មេដាយប្រាក់ស្ថាបនាជាតិ :

- លោក Tan Sri Dato' Soong Siew Hoong អគ្គលេខាធិការ នៃ សមាគមសភាពាណិជ្ជកម្ម ឧស្សាហកម្មចិន នៅ Malaysia កៅអី ចំនួន ១១៥ = ៥.៨៧៧.៦៣ USD

គ- មេដាយសំរឹទ្ធស្ថាបនាជាតិ :

១- លោក Michael Shak សហគ្រាស Micshak (Malaysia) អំពូលភ្លើង = ៤.៦៧៤ USD
២- លោក Yu Keng Seng នាយកគ្រប់គ្រងក្រុមហ៊ុនថ្នាំលាប OD PAINTS SDN - BHD (Malysia ) ថ្នាំលាប ២.២៧៣. ៤០ USD
៣- លោកឧកញ៉ា តុង សុចន្ធា បានធ្វើវិភាគទាន : ៣.០០០ USD
៤- លោកឧកញ៉ា ស្រី លាងឈាង បានធ្វើវិភាគទាន : ២.០០០ USD
៥- លោកជំទាវ កែវ ម៉ាលី បានធ្វើវិភាគទាន : ២.០០០ USD
៦- លោកស្រី ពឹង សុខា បានធ្វើវិភាគទាន : ២.០០០ USD
៧- លោក គុម គឹមសុន បានធ្វើវិភាគទាន : ២.០០០ USD
៨- លោក ចាន់ ហ៊ុយលួង បានធ្វើវិភាគទាន : ២.០០០ USD
៩- លោក ចាន់ ម៉ែន បានធ្វើវិភាគទាន : ១.០០០ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបន្ទាយមានជ័យ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសំរិទ្ធស្ថាបនាជាតិ** ជូនសប្បុរសជន ខ្មែរនៅសហរដ្ឋអាមេរិក ០២ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ក្នុងការទិញអង្ករចែកជូនប្រជាជន នៅឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក **លាវ ឃុនគី** អ្នកស្រី **តាំ សឿត** ថវិកាចំនួន ១.៣៦០ ដុល្លារអាមេរិក

២-លោក **ប៊ិច សារួន** អ្នកស្រី **ម៉ាម ឈន់** ថវិកាចំនួន ១.៣៦០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ ✓

ឆ្នាំទី ៩ លេខ ២៨ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ២០០៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

មាត្រា ១ : ត្រូវបានបំពាក់**មេដាយមាសស្ថាបនាជាតិ** ជូនតំណាងរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន ០១រូប និងសហគមន៍ ០១ ដែលបានជួយសាងសង់អាគារសិក្សា ០២ខ្នង មាន ១០បន្ទប់ នៅសាលាបឋមសិក្សាគ្រួស ឃុំរលាប្អៀរ និងសាលាបឋមសិក្សាជ្រៃបាក់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់សរុប ចំនួន ៤៧.៨៦៦ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឯកឧត្តម GOTARO OGAWA ឯកអគ្គរាជទូតជប៉ុនជាតំណាងរាជរដ្ឋាភិបាលនិងប្រជាជនជប៉ុន

២-សហគមន៍មិត្តភាព អាស៊ី ខ្មែរ ( KAFS )

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧៨ អនក្រ/តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ / អនក្រ.បក / ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : តែងតាំងលោក **អ៊ិន សាឡឿន** ជាជាវីបេសកកម្មអមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយករង សំរាប់បំពេញបេសកកម្មដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់ជូន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ សសរ

# សេចក្តីសម្រេច

ស្តីពី

## ការបង្កើតក្រុមការងារចុះត្រួតពិនិត្យធាតុភាព នៅប្រាសាទព្រះវិហារ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ថៃ

-យោងតាមតំរូវការចាំបាច់

## សំរេច

ប្រការ១: បង្កើតក្រុមការងារចុះត្រួតពិនិត្យធាតុភាពនៅប្រាសាទព្រះវិហារដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម វ៉ា គឹមហុង | ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន | ប្រធាន |
| ២-ឯកឧត្តម ឡុង ផុល | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |

| | | |
|---|---|---|
| ៣-ឯកឧត្តម រស់ រ៉េន | អនុរដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ | សមាជិក |
| ៤-ឯកឧត្តម ឡុង វិសាលោ | អនុរដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ | នាយរងសេនាធិការចំរុះ និងជានាយកទិវាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦-ឯកឧត្តម ព្រាប តាន់ | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ៧-ឧត្តមសេនីយ៍ទោ ជា ម៉ន | មេបញ្ជាការយោធភូមិភាគ៤ | សមាជិក |
| ៨-លោក ហ៊ួន សារ៉ាង | អគ្គនាយករងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

ប្រការ២ : ក្រុមការងារចុះត្រួតពិនិត្យបាតុភាពនៅប្រាសាទព្រះវិហារ មានភារកិច្ចដូចខាងក្រោម :

ក-ពិនិត្យបាតុភាពដែលកើតមានឡើងដោយភាគីថៃ ធ្វើការសាងសង់សាលាសំណាក់នៅមុខផ្លូវចូលក្នុងបរិវេណប្រាសាទព្រះវិហារ ។

ខ-ពិនិត្យនិងដោះស្រាយរាល់បញ្ហាទាក់ទងនឹងការសាងសង់ដោយភាគីថៃ ដោយយោងទៅលើគោលការណ៍ដែលគណៈកម្មការចំរុះព្រំដែនកម្ពុជា-ថៃ បានឯកភាពគ្នាក្នុងកំណត់ហេតុនៃកិច្ចប្រជុំលើកទី១ និងលើក ទី២ ។

គ-ចរចាជាមួយភាគីថៃ ដើម្បីរក្សាស្ថានភាពដដែល នៅតំបន់ប្រាសាទព្រះវិហារ ដោយចៀសវាងធ្វើសកម្មភាពណាដែលនាំឱ្យប៉ះពាល់ដល់ខ្សែព្រំដែនអន្តរជាតិរវាងប្រទេសទាំងពីរ នៅក្នុងតំបន់នោះ ។

ឃ-ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងការចរចាជាមួយភាគីថៃ ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ៣ : គ្រប់សមាជិកនៃក្រុមការងារចុះត្រួតពិនិត្យបាតុភាពនៅប្រាសាទព្រះវិហារ ត្រូវចូលប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ៤ : ក្រុមការងារនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនេះ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *កាលប្បវត្តិ-ឯកសារ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ដើម្បីពិនិត្យ វាយតម្លៃឡូត៍នេសាទសិក្សាស្រាវជ្រាវ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រ ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- យោងតាមការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យវាយតម្លៃឡូត៍នេសាទសិក្សាស្រាវជ្រាវដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ច័ន្ទ សុខអ៊ីទ** | រដ្ឋមន្ត្រីស្តីទី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម | **អ៊ឹក រ៉ាច៊ិន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម | **ច័ន្ទ សារុន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤-ឯកឧត្តម | **ម៉ឺន អ៊ុយ** | អនុរដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ៥-ឯកឧត្តមអភិបាលខេត្ត-ក្រុង ដែលមានឡូត៍នេសាទ | | សមាជិក |
| ៦-លោក ណៅ ធួក | ប្រធាននាយកដ្ឋានជលផល | សមាជិក |
| ៧-លោក ភាំង ឃាងខំណន | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក ញិម ចន់ថេត | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-លោក អេង ជាសាន | អនុប្រធាននាយកដ្ឋានជលផល | លេខាធិការ |

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

- ចុះពិនិត្យវាយតម្លៃតាមសភាពការណ៍ជាក់ស្តែងល្ងើឡូត៍នេសាទសិក្សាស្រាវជ្រាវដែលនៅសេសសល់ ។
- ពិភាក្សាលើកយោបល់អំពីទិដ្ឋភាពច្បាប់ ទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពសេដ្ឋកិច្ច និង សង្គម ។
- រាយការណ៍អំពីលទ្ធផលការងារ និង លើកអំពីវិធានការដោះស្រាយជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ដើម្បីអោយការងារធ្វើអាជីវកម្មនេសាទ បានទាន់រដូវនេសាទឆ្នាំ ២០០១ ។

ប្រការ ៣ : គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការជាជំនួយការតាមការចាំបាច់ ហើយមានសិទ្ធិប្រើប្រាស់ត្រាបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ប្រការ ៤ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការនេះត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១០ សរ.ណន**

## សារាចរណែនាំ

## ស្ដីពី

## ការប្រារព្ធទិវាអក្ខរកម្មជាតិ៨កញ្ញា

~~~~~~~~~~~~

អក្ខរកម្មជាកូនសោនៃការអភិវឌ្ឍសំរាប់គ្រប់ប្រទេសនៅក្នុងពិភពលោក ។ គ្រប់ប្រទេសសុទ្ធតែយល់ពីសារៈសំខាន់ចាំបាច់នៃចលនាអក្ខរកម្ម ។ ហេតុនេះហើយនៅឆ្នាំ ១៩៦៥ មហាសន្និបាតអក្ខរកម្មអន្តរជាតិបានរៀបចំឡើងនៅទីក្រុង តេអេរ៉ង់ ប្រទេសអ៊ីរ៉ង់ ។ ក្នុងពេលសន្និបាតនោះ អង្គប្រជុំបានសំរេចយកថ្ងៃទី ៨ កញ្ញា រៀងរាល់ឆ្នាំ សំរាប់ប្រារព្ធជាទិវាអក្ខរកម្មអន្តរជាតិ ។

នៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលត្រូវប្រារព្ធទិវាអក្ខរកម្មជាតិនៅថ្ងៃទី ៨ កញ្ញា ដោយអនុវត្តតាមព្រះរាជក្រឹត្យលេខ នស.រកត ០៩០០ / ១៦៣ ចុះថ្ងៃទី ៧ កញ្ញា ឆ្នាំ ២០០០ ។

ដើម្បីអនុវត្តតាមស្មារតីនៃមហាសន្និបាតអក្ខរកម្មអន្តរជាតិ និង តាមព្រះរាជក្រឹត្យខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាចេញសេចក្ដីណែនាំដល់គ្រប់ស្ថាប័ន ខេត្ត-ក្រុង អោយរៀបចំពិធីប្រារព្ធទិវាអក្ខរកម្មជាតិនៅថ្ងៃទី ៨ កញ្ញា ២០០១ ដែលមានខ្លឹមសារដូចខាងក្រោម :

១- ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំការប្រជុំនៅថ្នាក់ជាតិ នាថ្ងៃទី ៨ កញ្ញា ឆ្នាំ ២០០១ ដើម្បីផ្សព្វផ្សាយនូវគោលនយោបាយ ស្ដីពីការងារអប់រំក្រៅប្រព័ន្ធ ដោយមានការចូលរួមពីមន្ត្រីថ្នាក់ជាតិ ក្រសួង ស្ថាប័ន រាជធានី ខេត្ត-ក្រុង និង អង្គការនានា ។

២- ខេត្ត -ក្រុង ត្រូវរៀបចំ :

ក- បិទបដា ពាក្យស្លោក នៅតាមអង្គភាពនិង ទីប្រជុំជន រយៈពេល ៣ថ្ងៃ ពីថ្ងៃទី ៨ ដល់ ទី ៩ ខែ កញ្ញា ឆ្នាំ ២០០១ ។

ខ- មិទ្ទិញ ឬប្រជុំមន្ត្រីរាជការនិងប្រជាជន ឬ រៀបចំជាពិធីបើកថ្នាក់អក្ខរកម្ម ឬ ពិធីចែករង្វាន់ដល់សិស្ស គ្រូអក្ខរកម្ម ឬ ប្រគល់វិញ្ញាបនបត្រអក្ខរកម្ម ឬ ប្រលងជ្រើសរើសសិក្ខាកាមអក្ខរកម្មពូកែ ដែលមានស្នាដៃល្អ ឬ ការសំដែងសិល្បៈ ក្នុងន័យឃោសនាបំផុសឧបត្ថម្ភ និង ការចូលរួមក្នុងចលនាអក្ខរកម្ម ។
~~~~~~~~~~~~

៣- ក្រសួងពត៌មានត្រូវរៀបចំកម្មវិធីពិសេសថ្ងៃទី ៨ កញ្ញានេះ ដូចជាសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍ជាតិ។

៤- គណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំបូកសរុបវាយតំលៃការងារនេះ ដែលបានអនុវត្តកន្លងមក និង លើកទិសដៅទៅឆ្នាំខាងមុខ។

ទទួលបានសារាចរណែនាំនេះ គណៈរដ្ឋមន្ត្រីសូមអោយឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយ និង រៀបចំអនុវត្តអោយទទួលបានលទ្ធផលខ្ពស់ រួចហើយធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំពិធីនេះមកក្រសួងអប់រំ យុវជន និង កីឡា ដើម្បីបូកសរុបជូនគណៈរដ្ឋមន្ត្រីអោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០១ (គំរូជូនភ្ជាប់)។

ភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កំណត់ផ្ញើ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីទូលថ្វាយ និង គោរពជូនជ្រាបជាពត៌មាន"

-គ្រប់ក្រសួង ស្ថាប័ននានា

-គ្រប់អភិបាល ខេត្ត ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

## ឯកសារស្រាវជ្រាវ

១- ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០០/១៦៣ ចុះថ្ងៃទី ០៧ កញ្ញា ២០០០

២- គោលការណ៍ទាំង ៦ ស្តីពីវេទិកាអប់រំពិភពលោកពីថ្ងៃទី ២៦ ដល់ ២៨ មេសា ឆ្នាំ ២០០០ (ទីក្រុងដាកា ប្រទេស សេណេហ្គាល់)

## ពាក្យស្លោក

១- ជាតិ សាសនា ព្រះមហាក្សត្រ

២- ជយោ ព្រះរាជាណាចក្រកម្ពុជា

៣- អបអរសាទរ ទិវាអក្ខរកម្មជាតិ ៨ កញ្ញា

៤- រៀនហើយ រៀនទៀត រៀនពេញមួយជីវិត

៥- អប់រំសំរាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីអប់រំ

៦- រៀនដើម្បីអភិវឌ្ឍខ្លួនឯង និង សង្គមជាតិ

៧- អក្ខរកម្មជាកូនសោរនៃការអភិវឌ្ឍ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អភិបាលខេត្ត

......................................

# របាយការណ៍
## ស្តីពីលទ្ធផល
## នៃការប្រារព្ធខួបទិវាអក្ខរកម្មជាតិ ៨ កញ្ញា

~~~~~~~~~~~~~~~~~

I- ពេលវេលារៀបចំទិវា .........................................................................................................

II- រូបភាពនៃការរៀបចំ .........................................................................................................

.........................................................................................................

.........................................................................................................

.........................................................................................................

III- លទ្ធផលប្រជុំគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធខេត្ត

.........................................................................................................

.........................................................................................................

.........................................................................................................

IV- សកម្មភាពសិស្ស

.........................................................................................................

.........................................................................................................

.........................................................................................................

V- សកម្មភាពចូលរួមរបស់ប្រជាជន

.........................................................................................................

.........................................................................................................

.........................................................................................................

VI- សន្និដ្ឋាន និង វាយតំលៃលទ្ធផល

.........................................................................................................

.........................................................................................................

..............ថ្ងៃទី..........ខែ...............ឆ្នាំ ២០០១

អភិបាលខេត្ត
~~~~~~~~~~~~~~~~~

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ : ៥១៥ សហវ.

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេស លើទំនិញ និង សេវាមួយចំនួនសំរាប់បារី

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៤/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃ ទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញប្រកាសលេខ ០៦៧ សហវ/ប្រក/គរ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និង សេវាមួយចំនួនចំពោះទំនិញនាំចូល
- បានឃើញប្រកាសលេខ ៣៤១ ប្រក/សហវ/ពដ ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និង សេវាមួយចំនួន
- បានឃើញការចាំបាច់ក្នុងការគ្រប់គ្រងប្រមូលអាករពិសេសលើបារីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៤. ការលើកលែងការបិទតែមប្រើអាករ**

១. ត្រូវបានលើកលែងការបិទតែមប្រើអាករ ចំពោះផលិតផលិតនៅក្នុងស្រុកដែលសំរាប់ធ្វើការនាំចេញ ឬ បារីនាំចូលពីបរទេសដែលសំរាប់ធ្វើការនាំចេញទៅវិញ ។

២. ចំពោះបុគ្គលដែលគ្មានភាតព្វកិច្ចចុះបញ្ជីជាវត្ថុលជាប់អាករពិសេសលើទំនិញ និង សេវាមួយចំនួន (អពទស) អាចនាំចូលបារីដោយរួចអ អពទស និង លើកលែងការបិទតែមប្រើអាករលើបារីចំនួន ២០០ ដើម ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ នៃប្រកាស លេខ ៣៨១ ប្រក.សហវ.ពជ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៥. ភាតព្វកិច្ចចុះបញ្ជី**

១. អ្នកផលិតបារីនៅក្នុងស្រុក ឬ អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាប់អាករតាមបទប្បញ្ញត្តិស្តីពីអាករពិសេសលើទំនិញ និង សេវាមួយចំនួន ទោះបីសំរាប់លក់នៅក្នុងស្រុក ឬ សំរាប់នាំចេញ ឬ សំរាប់នាំចេញទៅវិញក្តី ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ មុនពេលចាប់ផ្តើមផលិតបារី ឬ នាំចូលបារី ។ នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ មិនអនុញ្ញាតឱ្យធ្វើការផលិតបារី ឬ នាំចូលបារីដោយពុំមានការចុះបញ្ជីជាមុនឡើយ ហើយអាចបដិសេធចោលនូវការចុះបញ្ជីណាមួយ ប្រសិនបើអ្នកចុះបញ្ជីមិនបានបំពេញតាមបែបបទនៃប្រកាសនេះ ។

២. អ្នកផលិតបារីនៅក្នុងស្រុក ឬ អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារបានស្រេចបាច់នៅមុនថ្ងៃប្រកាសនេះចុះហត្ថលេខា ពុំមានភាតព្វកិច្ចត្រូវចុះបញ្ជីតាមបែបបទ និង វិធីដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះទេ ។

៣. វិធានចុះបញ្ជីមិនត្រូវអនុវត្តទេចំពោះរូបវន្តបុគ្គលដែលនាំចូលបារីសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ។ រូបវន្តបុគ្គលអ្នកនាំចូលបារីសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនដែលគ្មានភាតព្វកិច្ចចុះបញ្ជីនេះ មិនត្រូវបានលើកលែងទេអំពីភាតព្វកិច្ចបង់ប្រាក់អាករលើទំនិញជាប់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី ។

## ជំពូកទី ២

## តែមប្រើអាករ

**ប្រការ ៦. ផែនការផលិត និងការបោះពុម្ពតែមប្រើអាករ**

១. តែមប្រើអាករលើបារីត្រូវបានបោះពុម្ពដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយផ្អែកលើផែនការផលិត និង នាំចូលបារីប្រចាំឆ្នាំរបស់អ្នកផលិតបារី និង អ្នកនាំចូលបារី ។

២. រៀងរាល់ឆ្នាំសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែកក្កដា អ្នកផលិតបារី ត្រូវផ្តល់ផែនការផលិតបារីនៃឆ្នាំបន្ទាប់មកនាយកដ្ឋានពន្ធដារ ។ ចំពោះអ្នកនាំចូលបារី ត្រូវផ្តល់ផែនការនាំចូលបារីនៃឆ្នាំបន្ទាប់មកទីចាត់ការគយ និង រដ្ឋាករ ។

៣. នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ ទទួលបន្ទុកគ្រប់គ្រង និង លក់តែមប្រើអាករ ។

## ប្រការ ៧. ការទិញតែមប្រើអាករ

១. អ្នកផលិតបារីនៅក្នុងស្រុក និង អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំទិញតែមប្រើអាករតាមគំរូកំណត់ដោយនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែទី ៣ នៃត្រីមាសនីមួយៗ ។

២. នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ មានភារកិច្ចរក្សាបញ្ជីកត់ត្រាតែមប្រើអាករដែលបានបើកផ្តល់ជូនទាំងអស់ ដែលរួមមានឈ្មោះសហគ្រាសផលិតបារីនៅក្នុងស្រុក ឬ អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា និង កាលបរិច្ឆេទនៃការបើកផ្តល់តែមប្រើអាករទាំងនោះ ។

## ប្រការ ៨. តម្លៃ និង លក្ខណៈសំគាល់នៃតែមប្រើអាករ

១. តម្លៃ និង លក្ខណៈសំគាល់នៃតែមប្រើអាករ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ៩. ការបង្វិលសងតែមប្រើអាករដែលមិនបានប្រើប្រាស់

១. អ្នកផលិតបារីនៅក្នុងស្រុក និង អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា អាចបង្វិលសងសន្លឹកតែមប្រើអាករដែលមិនបានប្រើប្រាស់មកនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ ដើម្បីនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ ទូទាត់សងវិញនូវប្រាក់ថ្លៃសន្លឹកតែមប្រើអាករដែលមិនបានប្រើប្រាស់ទាំងនោះ ឬ ប្តូរជាមួយសន្លឹកតែមប្រើអាករថ្មី ។ ការប្តូរនេះត្រូវផ្អែកលើតម្លៃជាក់ស្តែងនៃសន្លឹកតែមប្រើអាករថ្មីក្នុងរយៈពេលនីមួយៗ ។

២. ការបង្វិលសងតែមប្រើអាករដែលមិនបានប្រើប្រាស់ ត្រូវធ្វើឡើងក្នុងរយៈពេល ១ ឆ្នាំម្តង ចាប់ពីថ្ងៃដែលនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ បានបញ្ចេញឱ្យប្រើប្រាស់តែមប្រើអាករនោះមក ។

## ប្រការ ១០. ការបង្វិលសងតែមប្រើអាករដែលខូចខាត

១. អ្នកផលិតបារីនៅក្នុងស្រុក ឬ អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា អាចទាមទារសុំបង្វិលសងប្រាក់ថ្លៃសន្លឹកតែមប្រើអាករលើបារីដែលខូចខាតក្នុងពេលប្រតិបត្តិការផលិតកម្មផ្ទាល់ពីនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ ដោយភ្ជាប់មកជាមួយនូវសន្លឹកតែមប្រើអាករដែលខូចខាតនោះ ឬ ប្តូរជាមួយសន្លឹកតែមប្រើអាករថ្មី ។ ការប្តូរនេះត្រូវផ្អែកលើតម្លៃជាក់ស្តែងនៃសន្លឹកតែមប្រើអាករថ្មីក្នុងរយៈពេលនីមួយៗ ។

២. កំរិតនៃការខូចខាតនៃសន្លឹកតែមប្រើអាករ គឺមិនអនុញ្ញាតឱ្យលើសពី ១% នៃសន្លឹកតែមប្រើអាករដែលបានទិញទេ ។

## ប្រការ ១១. ការសុំទិញតែមប្រើអាករបន្ថែម

១. ក្នុងករណីមានការបង្កើនបរិមាណផលិតផលបារី ឬ បរិមាណនាំចូលបារីលើសពីចំនួនដែលបានប្រកាសជូននាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ អ្នកផលិតបារី ឬ អ្នកនាំចូលបារី អាចស្នើសុំទិញតែមប្រើអាករបន្ថែមនៅនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករ ។ ការស្នើសុំទិញសន្លឹកតែមប្រើអាករបន្ថែមនេះ ត្រូវធ្វើតាមទម្រង់បែបបទដែលនាយកដ្ឋានពន្ធដារ ឬ ទីចាត់ការគយ និង រដ្ឋាករបានកំណត់ ។

# ជំពូកទី ៣
# ការតម្រូវចំពោះអ្នកផលិតបារី និង អ្នកនាំចូលបារី

**ប្រការ ១២.**

១. ចំពោះអត្រាអាករ កាតព្វកិច្ចរបស់បុគ្គលចុះបញ្ជី ការផ្គត់ផ្គង់ដោយខ្លួនឯង កំណត់ត្រាគណនេយ្យ វិក្កយបត្រ ការទុកដាក់ឯកសារ ការគណនាប្រាក់អាករត្រូវបង់ ការបង់អាករ ការចុះបញ្ជីឃ្លាំងស្តុកបារី ទីតាំងឃ្លាំង និង ការតម្រូវចំពោះការស្តុកបារី អ្នកផលិតបារីនៅក្នុងស្រុក ឬ អ្នកនាំចូលបារីមកក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ច ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី១.២ ផ្នែកទី ២.១ ផ្នែកទី ២.២ ផ្នែកទី២.៤ ផ្នែកទី៤.១ ផ្នែកទី៤.២ ផ្នែកទី៤.៧ ផ្នែកទី៤.៨ ផ្នែកទី៦.១ ផ្នែកទី៦.២ ផ្នែកទី៧.១ ផ្នែកទី៨.១ ផ្នែកទី៨.២ និង ផ្នែកទី៨.៣ នៃប្រកាសលេខ ៣៤១ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និង សេវាមួយចំនួន ។

# ជំពូកទី ៤
# ការត្រួតពិនិត្យ និង ទោសទណ្ឌ

**ប្រការ ១៣. ការត្រួតពិនិត្យ**

១. នាយកដ្ឋានពន្ធដារមានសិទ្ធិអំណាចត្រួតពិនិត្យរោងចក្រ កន្លែងផលិត ឃ្លាំងស្តុក ឬ កន្លែងលក់បារី និង មធ្យោបាយដឹកជញ្ជូន ។

២. ទីចាត់ការគយ និង រដ្ឋាករ មានសិទ្ធិត្រួតពិនិត្យតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីគយ និង រដ្ឋាករ ។

**ប្រការ ១៤. ការគេចវេសពន្ធ**

១. ការមិនបានបំពេញកាតព្វកិច្ចបិទតែមប្រ៍អាករដូចមានចែងក្នុងកថាខ័ណ្ឌ ១ ប្រការ ៣ នៃប្រកាសនេះ ដោយរួមបញ្ចូលទាំងការលក់បារីដែលមិនមានបិទតែមប្រ៍អាករ ត្រូវបានចាត់ទុកជាការគេចវេសពន្ធ ដូចមានចែងក្នុង មាត្រា ១២៧ និង ក្រៅពីទោសទណ្ឌផ្សេងទៀត ត្រូវរងការផ្តន្ទាទោសតាមមាត្រា ១៣៥ នៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ ១៥. អំពើរាំងស្ទះ**

១. ការក្លែងបន្លំ ការប្រើប្រាស់ជាថ្មីនូវតែមប្រ៍អាករដែលបានបិទរួច ត្រូវចាត់ជាអំពើរាំងស្ទះការអនុវត្តន៍ បទប្បញ្ញត្តិស្តីពីសារពើពន្ធ ដូចមានចែងក្នុងមាត្រា ១២៨ និង ក្រៅពីទោសទណ្ឌផ្សេងទៀត ត្រូវបង់ពន្ធបន្ថែម ព្រមទាំងរងការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១៣៣ និង មាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ ១៦. ការឃាត់ទុក**

១. បន្ថែមលើបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ១៤ និង ប្រការ ១៥ នៃប្រកាសនេះ ក្នុងករណីគេឃើញបារីដែលមិនបានបិទតែមប្រើអាករ បិទតែមប្រើអាករក្លែងក្លាយ បិទតែមប្រើអាករដែលបានប្រើប្រាស់រួចហើយ នាយកដ្ឋានពន្ធដារ ឬ មន្ទីរគយ និង រដ្ឋាករ ត្រូវធ្វើការឃាត់ទុក និង គ្រប់គ្រងបារីទាំងនោះ ។

២. ប្រសិនបើបារីដែលបានឃាត់ទុកទាំងនោះត្រូវបានស្គាល់ប្រភពផលិត ឬ នាំចូល អ្នកផលិត ឬ អ្នកនាំចូលត្រូវទិញបារីដែលបានឃាត់ទុកនោះវិញ ក្នុងតម្លៃស្មើនឹងថ្លៃលក់នៅលើទីផ្សារនៅពេលដែលគេឃើញ ។

៣. ក្នុងករណីមិនត្រូវបានស្គាល់ប្រភពផលិត ឬ នាំចូល បារីដែលត្រូវបានឃាត់ទុកនោះ នឹងត្រូវធ្វើការបំផ្លាញចោល ឬ ដាក់លក់ដោយវិធីដេញថ្លៃ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនដំណឹង"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីអនុវត្ត"
- គ្រប់អង្គភាពពន្ធដារ-មន្ទីរគយ និង រដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១




របៀបបិទតែមប្រើអាករលើបារីកញ្ចប់រឹង

របៀបបិទតែមប្រើអាករលើបារីកញ្ចប់ទន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No.៦០៤ MoC / M 2001

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់
## ដែលត្រូវបាននាំចេញទៅកាន់សហរដ្ឋអាមេរិកសំរាប់ឆ្នាំ ២០០១

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រិត្យលេខ នស/រក្រ/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រិត្យលេខ ០១៩៦/១៦/ អនក្រ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រិត្យលេខ ៥៤អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីអំពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម ទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស, ខ្សែន, សសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស, សសៃរុក្ខជាតិគ្មានជាតិកប្បាស និង សសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជានិង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩
- យោងស្មារតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ៣៦០ពណ៩៩ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុនៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក
- បានឃើញការចាំបាច់របស់ក្រសួង

## ស ំ រេ ច

**ប្រការ ១:** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និង ដែលបានចុះបញ្ជីនៅ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ត្រូវបានអញ្ជើញអោយមកដេញថ្លៃតាមប្រភេទផ្សេងៗនៃកូតា ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន។

**ប្រការ ២:** រោងចក្រនីមួយៗត្រូវបានអនុញ្ញាតអោយដេញថ្លៃ ដោយគ្មានកំណត់បរិមាណកូតា ដែលដាក់ដេញថ្លៃ តាមប្រភេទនីមួយៗដូចខាងក្រោម:

| Category | Tender Quantity | Quantity per Batch |
|---|---|---|
| 334/634 | 11,000 doz | មិនកំណត់បរិមាណ |
| 335/635 | 2,800 doz | មិនកំណត់បរិមាណ |
| 338/339 | 29,000 doz | មិនកំណត់បរិមាណ |
| 340/640 | 60,000 doz | មិនកំណត់បរិមាណ |
| 345 | 13,000 doz | មិនកំណត់បរិមាណ |
| 445/446 | 20,000 doz | មិនកំណត់បរិមាណ |
| 638/639 | 60,000 doz | មិនកំណត់បរិមាណ |
| 645/646 | 60,000 doz | មិនកំណត់បរិមាណ |



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

**ប្រការ ៣:** ពាក្យដេញថ្លៃនីមួយៗត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានការបញ្ជាក់ពីធនាគារ " Certified Check" ដែលមានតម្លៃ ស្មើនឹង ១០ % នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រ នេះត្រូវទូទាត់ជូន គណៈកម្មការគ្រប់គ្រងកូតានាំចេញ (EQMC) ។ ការបង់ប្រាក់កក់ អប្បបរមាមិនគ្រប់ចំនួន ១០ % នៃ តំលៃសរុប នឹងត្រូវចាត់ទុកជា ពាក្យសុំដេញថ្លៃ ដែលមិនគ្រប់លក្ខណៈសម្បត្តិ ចូលរួមដេញថ្លៃ ។

ឧទាហរណ៏ : រោងចក្រ A ដេញថ្លៃ

២០.០០០ ឡូ តំលៃ ៨ ដុល្លា ក្នុងមួយឡូ= ១៦០.០០០ ដុល្លា

សរុប ១៦០.០០០ ដុល្លា

ប្រាក់កក់ ១០ % គឺ ១៦.០០០ ដុល្លា ។

**ប្រការ ៤ :** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាមប្រភេទកូតានីមួយៗ នឹងត្រូវចាត់ទុកថា ជាការដេញថ្លៃ ដែលបាន ទទួលជ័យជំនះ ។ បរិមាណកូតានឹងត្រូវបានបែងចែក ជូនអ្នកដេញថ្លៃម្នាក់ៗ ដែលបានទទួលជោគជ័យ រហូតដល់បរិមាណកូតាសរុប ត្រូវបានបែងចែកអស់ជាស្ថាពរ ។

**ប្រការ ៥ :** កូតាដែលមិនទាន់បែងចែក នឹងបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយទៀត ។

**ប្រការ ៦ :** តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួន ទសភាគ 50 សេន ដុល្លា អាមេរិក លើថ្លៃឯកត្តា ។

| Category | Minimum Bid | Category | Minimum Bid |
|---|---|---|---|
| 334/634 | US$ 4.00 | 345 | US$ 5.00 |
| 335/635 | US$ 5.00 | 445/446 | US$ 2.00 |
| 338/339 | US$ 5.00 | 638/639 | US$ 1.00 |
| 340/640 | US$ 1.00 | 645/646 | US$ 1.00 |

**ប្រការ ៧ :** ពាក្យសុំដេញថ្លៃត្រូវដាក់ជូន ប្រធានគណៈកម្មការគ្រប់គ្រងកូតានាំចេញ " EQMC " នៃក្រសួង ពាណិជ្ជកម្ម, ដែលមានទីតាំង នៅអាគារលេខ ២០A ជាន់ទី២, មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃ

ត្រូវដាក់ក្នុង ស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០% នៃតំលៃដេញថ្លៃសរុបពីខាងក្រៅស្រោមសំបុត្រនោះ សំរាប់ជាការផ្ទៀងផ្ទាត់ ។

**ប្រការ ៨ :** កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ វេលាម៉ោង ៨:០០ ព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម អាគារលេខ ២០A ជាន់ទី២ មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ ។

**ប្រការ ៩ :** កាលបរិច្ឆេទឈប់ទទួលពាក្យសុំដេញថ្លៃ ត្រូវកំណត់នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០១ វេលាម៉ោង ១៧:០០ ល្ងាច ។

**ប្រការ ១០:** លទ្ធផលនៃការដេញថ្លៃនឹងត្រូវប្រកាសជាសាធារណៈ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០១ វេលាម៉ោង ៨:០០ ព្រឹក ។

**ប្រការ ១១:** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ នឹងអាចទទួលយកកូតារបស់ខ្លួន ទៅប្រើប្រាស់បាន ចាប់ពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០១ បន្ទាប់ពីបានទូទាត់ តំលៃដេញថ្លៃដែលនៅសេសសល់ រួចហើយ ។

**ប្រការ ១២:** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ ហើយខកខានមិនបានទទួលយក បរិមាណកូតារបស់ខ្លួន នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០១ទេ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតា ដែលមិនបានទទួលយកនោះ ត្រូវបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយ ។

**ប្រការ ១៣:** អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវផ្តល់ជូនវិញភ្លាមនូវប្រាក់កក់ ១០% របស់ខ្លួន ។

**ប្រការ ១៤:** កូតាដែលទទួលបានតាមរយៈការដេញថ្លៃនេះ នឹងត្រូវបានប្រើប្រាស់សំរាប់តែឆ្នាំសារពើពន្ធ ២០០១ ប៉ុណ្ណោះ, យោងតាម កិច្ចព្រមព្រៀងវាយនភ័ណ្ឌរវាងសហរដ្ឋអាមេរិក និងកម្ពុជា នាឆ្នាំ១៩៩៩ ។

បណ្ណាល័យជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

**ប្រការ ១៥ :** សេចក្តីសំរេចរបស់គណៈកម្មការគ្រប់គ្រងកូតានាំចេញ នៅក្នុងការអនុវត្តការដេញថ្លៃនេះ គឺជាការសំរេចចុងក្រោយ ។

**ប្រការ ១៦ :** នាយកខុទ្ទកាល័យ, អគ្គនាយកបច្ចេកទេស, ប្រធាននាយកដ្ឋានកាំកុងត្រូល, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានរដ្ឋបាល, ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតានាំចេញ ត្រូវអនុវត្តប្រកាសនេះអោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- រាជកិច្ច
- ទូរទស្សន៍ជាតិ, វិទ្យុជាតិ និង កាសែតជាតិ "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ